ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ

# PATENT TAX COLLECTION PROCESS OF GENERAL DEPARTMENT OF TAXATION

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៤

PHNOM PENH-2024

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់ អគ្គនាយកដ្ឋានពន្ធដារ

PATENT TAX COLLECTION PROCESS OF GENERAL DEPARTMENT OF TAXATION

សាស្ត្រាចារ្យណែនាំ៖ សាំង ចេក

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៤

PHNOM PENH-2024

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១**

**ប្រធានបទ៖ ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត ស្រេង ផល្លា

សាស្ត្រាចារ្យណែនាំ

សាំង ចេក

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត មាស សំណាង

ប្រធានគណៈកម្មការវាយតម្លៃ និងជាប្រធាន
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

គណៈកម្មការវាយតម្លៃទី៤

បេក្ខបណ្ឌិត យ៉ែម សុខហៀក

**នាយកវិទ្យាស្ថាន**

**បណ្ឌិត ហេង វ៉ាន់ដា**

នាយិការងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

(Impression)

យើងខ្ញុំបានរៀបចំចងក្រងសារណានេះឡើងមកក្នុងគោលបំណងអភិវឌ្ឍន៍នូវ ចំណេះដឹងដោយធ្វើការសិក្សាស្វែងយល់ឱ្យបានកាន់តែស៊ីជម្រៅទាំងទ្រឹស្តី និងការអនុវត្តព្រមទាំងពង្រីក និងពង្រឹងនូវការយល់ដឹងឱ្យកាន់តែប្រសើរឡើងថែមមួយកម្រិតទៀត។ ក្នុងនាមយើងខ្ញុំគឺជាក្រុមនិស្សិត ដែលបានសិក្សាជំនាញគណនេយ្យនៅវិទ្យាស្ថានវ៉ាន់ដាអស់រយៈពេល៤ឆ្នាំសិក្សាកន្លងមកនេះ ហើយធ្លាប់បានសិក្សាទៅលើមុខវិជ្ជាគណនេយ្យអនុវត្តន៍ និងពន្ធក៏ដូចជាមុខវិជ្ជាផ្សេងៗទៀតដែលទាក់ទងនឹងពន្ធ តាំងពីឆ្នាំទីពីរកន្លងមកក្រុមនាងខ្ញុំទាំងអស់គ្នានិងខិតខំប្រឹងប្រែងព្យាយាមឱ្យអស់ពីទាំងកម្លាំងកាយ និងកម្លាំងចិត្តក្នុងការរៀបចំចងក្រងនូវកិច្ចការស្រាវជ្រាវសារណាមួយនេះឡើងដោយមានសាស្ត្រាចារ្យអ្នកណែនាំ និងសាស្ត្រាចារ្យដែលបានជួយសម្របសម្រួល។

ទន្ទឹមនឹងនេះដោយឃើញថាគ្រប់មុខវិជ្ជាទាំងអស់សុទ្ធតែមានសារៈសំខាន់សម្រាប់ឱ្យនិស្សិតយកទៅប្រើប្រាស់ នៅក្នុងវិស័យការងារបាន ក៏ដូចជាជីវិតរស់នៅប្រចាំថ្ងៃ ជាពិសេសគឺមុខវិជ្ជាដែលទាក់ទងទៅនឹងពន្ធដារ ដែលស្ថាប័នត្រូវឲ្យបុគ្គលិកពាក់ព័ន្ធត្រូវមានចំណេះដឹងស្តីពីពន្ធដើម្បីរៀបចំ និងកាន់កាប់បញ្ជីគណនេយ្យឲ្យបានត្រឹមត្រូវស្របទៅតាមការណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីជៀសវាងរាល់នូវបញ្ហាផ្សេងៗ ដែលកើតមានឡើងនិងធ្វើឲ្យមានការរាំងស្ទះដល់ដំណើរការនៃការប្រកបអាជីវកម្មរបស់ប្រជាពលរដ្ឋទៅថ្ងៃក្រោយ។ ដោយក្រុមយើងខ្ញុំបានយល់ឃើញថាចំណេះដឹង ដែលទាក់ទងនឹងខាងពន្ធដារនេះពិតជាចំណេះដឹងបន្ថែមមួយដ៏មានសារៈសំខាន់ចំពោះនិស្សិត និងប្រជាពលរដ្ឋគ្រប់រូបដើម្បីសិក្សាស្វែងយល់ និងអភិវឌ្ឍន៏ខ្លួនឲ្យកាន់តែមានសមត្ថភាព និងក្លាយខ្លួនទៅជាធនធានមនុស្សមួយដល់សង្គមជាតិ។ ហេតុនេះហើយទើបក្រុមរបស់យើងខ្ញុំបានសម្រេចជ្រើសរើសយកប្រធានបទស្តីពី **«ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ»** យកមកសិក្សាស្រាវជ្រាវដែលមានគោលបំណងឲ្យអ្នកអាន និងអ្នកស្រាវជ្រាវក្រោយៗទៀតឱ្យយល់កាន់តែច្បាស់ស្តីពីពន្ធដារ និងបានចូលរួមចំណែកក្នុងការស្រាវជ្រាវដល់និស្សិតជំនាន់ក្រោយៗព្រមទាំងអ្នកដ៏ទៃផ្សេងទៀត។

ជាទីបញ្ចប់ ចំពោះការស្រាវជ្រាវសារណារបស់ក្រុមយើងខ្ញុំទាំងអស់គ្នាសូមអភ័យទោសទុកជាមុនទៅលើកំហុសខុសឆ្គងនិង ពាក្យពេចន៍ អក្ខរាវិរុទ្ធ អត្ថន័យខ្លឹមសារ និង ឃ្លោងឃ្លាត្រង់ចំណុចណាមួយដែលក្រុមយើងខ្ញុំបានបង្កើតឡើងឱ្យមានរាល់នូវកំហុសដោយអចេតនាណាមួយ។ បើទោះបីជាសារណានេះមិនទាន់បានបំពេញនូវតម្រូវការរបស់មិត្តនិស្សិតគ្រប់ជ្រុងជ្រោយនៅឡើយក៏ពិតមែនប៉ុន្តែ យើងខ្ញុំក៏ជឿជាក់ទៅលើកិច្ចការងារមួយនេះអាចប្រើប្រាស់ទុកជាទុនក្នុងការសិក្សាស្រាវជ្រាវ និងវិភាគត្រិៈរិះពិចារណាបន្ថែមទៅលើតួនាទីឱ្យបានល្អ។ យ៉ាងណាមិញពួកយើងរីករាយក្នុងការទទួលនូវការរិះគន់រាល់ការផ្តល់យោបល់ក្នុងន័យកែលម្អ ដើម្បីយកមកបំពេញនូវចំណុចខ្វះខាតផ្សេងៗនិងស្ថាបនាអភិវឌ្ឍន៍ដើម្បីពង្រីកនូវចំណេះដឹងបន្ថែមឱ្យកាន់តែល្អប្រសើរឡើងព្រោះនេះជាកិច្ចការ ស្រាវជ្រាវសារណាលើកដំបូងរបស់ក្រុមយើងខ្ញុំ។

# រចនាសម្ព័ន្ធក្រុម



សៅ លក្ខិណា
**B21/2266**

.



យ៉ា ឌីឡា
**B21/3296**



ឡឹង សុខឡេង
**B21/2622**



ឡាត់ ម៉ារី
**B21/2642**



អយ កញ្ញា
**B21/2253**

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំ ជានិស្សិតនៃវិទ្យាស្ថាន វ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១ ជំនាញគណនេយ្យ

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ៖**

លោកឪពុក និងអ្នកម្តាយជាអ្នកមានគុណដែលបានផ្តល់កំណើតដល់រូបកូន ព្រមទាំងបានចិញ្ចឹមបីបាច់មើលថែទាំកូនបានយ៉ាងល្អតាំងពីតូចរហូតដល់ធំជាមួយនឹងក្តីស្រលាញ់ដ៏ធំធេងបំផុត ដែលពុំអាចកាត់ថ្លៃបាន ហើយព្រមទាំងផ្គត់ផ្គង់ឱ្យកូននូវគ្រប់សព្វបែបយ៉ាង រួមទាំងការលើកទឹកចិត្ត និងការទូន្មានប្រៀនប្រដៅឱ្យកូនខិតខំសិក្សារៀនសូត្រ ដើម្បីទទួលបាននូវអនាគតមួយល្អប្រសើរតាំងពីកូនចូលរៀនដំបូងរហូតមកដល់ពេលនេះលើសពីនេះបានបង្រៀនកូនឱ្យស្គាល់នូវទង្វើល្អ និងទង្វើអាក្រក់ និងបានបង្រៀនឱ្យកូនចេះស្រលាញ់ជាតិមាតុភូមិកម្ពុជា។

ក្រុមនាងខ្ញុំ សូមសំដែងនូវក្តីគោរពដឹងគុណដ៏ជ្រាលជ្រៅទៅដល់ ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** នាយកនៃវិទ្យាស្ថានវ៉ាន់ដា និងគោរពទៅកាន់គណៈគ្រប់គ្រង បុគ្គលិក សាស្ត្រាចារ្យនៃវិទ្យាស្ថាន វ៉ាន់ដា ដែលជានិច្ចកាលតែងតែផ្តល់នូវការលើកទឹកចិត្ត និងទូន្មានល្អៗ អនុគ្រោះដល់រូបនាងខ្ញុំរហូតធ្វើឱ្យការសិក្សានាងខ្ញុំបានបញ្ចប់ទៅយ៉ាងរលូន និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ជាពិសេសក្រុមនាងខ្ញុំ សូមថ្លែងអំណរគុណទៅដល់សាស្ត្រាចារ្យណែនាំលោកស្រី **សាំង ចេក** ដែលលោកស្រីបានខិតខំឆ្លៀតពេលវេលាដ៏មានតម្លៃដើម្បីមកជួយណែនាំ ផ្តល់នូវយុទ្ធសាស្ត្រ និងលើកទឹកចិត្តដល់ការរៀបចំសរសេរសារណារបស់ក្រុមនាងខ្ញុំឱ្យកាន់តែមានភាពល្អប្រសើរ។

ជាទីបញ្ចប់ នាងខ្ញុំសូមលើកម្រាមដៃដប់សំពះបួងសួងដល់គុណព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោកឱ្យជួយបីបាច់តាមថែរក្សាដល់លោកអ្នកមានគុណខាងលើ ឱ្យជួបប្រទះតែសេចក្តីសុខទាំងផ្លូវកាយ និងផ្លូវចិត្តគ្រប់ពេលវេលាកុំបីអាក់ខានឡើយ។ សូមគោរពជូនពរដល់គុណូបការជនទាំងអស់ ឱ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺៈ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមនាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃវិទ្យាស្ថាន វ៉ាន់ដា ជំនាន់ទី២១៖ សូមធានាអះអាងយ៉ាងច្បាស់ថា ខ្លឹមសារសារណាក្រោមប្រធានបទ "ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ" នេះគឺជាស្នាដៃរបស់ក្រុមនាងខ្ញុំដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងកិច្ចការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ. ............... ខែ.......... ឆ្នាំ..... ...... ព.ស.២៥៦....

ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២....

**ហត្ថលេខាតំណាងក្រុម**

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

អគ្គនាយកដ្ឋានពន្ធដារ គឺមិនត្រឹមតែជាស្ថាប័នរដ្ឋមួយដែលមិនត្រឹមតែជួយរកចំណូលដល់ជាតិនោះទេប៉ុន្តែស្ថាប័នមួយនេះថែមទាំងជាស្ថាប័នមួយ ដែលជួយក្នុងការគ្រប់គ្រងទៅលើម្ចាស់អាជីវកម្ម សហគ្រាស ស្ថាប័នរដ្ឋ ឯកជន អង្គការ ម្ចាស់អាជីវកម្ម ក្រុមហ៊ុននានា ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនអោយបានត្រឹមត្រូវទៅតាមបទបញ្ញត្តិរបស់អគ្គនាយកដ្ឋានពន្ធដារដែលបានកំណត់ មិនត្រឹមតែមានច្បាប់ស្តីពីពន្ធដារយ៉ាងច្បាស់លាស់នោះ។ អគ្គនាយកដ្ឋានពន្ធដារបានចាប់ផ្តើមដំណើរការតាំងពីឆ្នាំ១៩៥៣ មកទល់នឹងពេលបច្ចុប្បន្ននេះសង្កេតឃើញថាការប្រតិបត្តិការទៅលើការអនុវត្តច្បាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ ពិតជាមានប្រសិទ្ធភាពខ្ពស់។

ឈរលើមូលដ្ឋាន ដែលជាកត្តានៅក្នុងការស្រាវជ្រាវនិងចងក្រងសារណាមួយនេះឡើង គឺស្វែងយល់អំពីចំណុចសំខាន់ៗនៃ "**ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ**" នៅក្នុងដំណើរការនេះផងដែរអគ្គនាយកដ្ឋានពន្ធដារបាន កំណត់កាលបរិច្ឆេទ កម្រិតអត្រាពន្ធ មធ្យោបាយនៃការបង់ពន្ធប៉ាតង់យ៉ាងច្បាស់ជូនទៅដល់អ្នកជាប់ពន្ធគ្រប់រូបក្នុងការអនុវត្តតាម។ អគ្គនាយកដ្ឋានពន្ធដារថែមទាំងបានសហការជាមួយក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងការងារ និងផ្សេងៗទៀតក្នុងការសម្រេចបាននូវការអនុវត្តយ៉ាងតឹងរឹងមួយនេះ ។

ក្រោយពីបានបញ្ចប់ការងារស្រាវជ្រាវទៅលើប្រធានបទមួយនេះរួចមក បានធ្វើឱ្យក្រុមយើងខ្ញុំយល់ឃើញកាន់តែច្បាស់អំពីច្បាប់ស្តីពីសារពើពន្ធរបស់អ្នកជាប់ពន្ធ និងសាធារណៈជនព្រមទាំងការអនុវត្តការងារប្រមូលពន្ធប៉ាតង់របស់រដ្ឋបាលសារពើពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារយ៉ាងម៉ត់ចត់ និងប្រកបដោយប្រសិទ្ធិភាពខ្ពស់។ បន្ទាប់ពីបានធ្វើកិច្ចការស្រាវជ្រាវរួចមកហើយនេះ ដែលទាក់ទង់ទៅនឹងប្រធានបទស្តីពី **ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ**រួចមកយើងខ្ញុំសង្កេតឃើញថា មានការរឹតបន្តឹងយ៉ាងហ្មត់ចត់ទៅលើការអនុវត្តច្បាប់ពន្ធប៉ាតង់ទៅលើអ្នកជាប់ពន្ធនានា ដែលបានប្រកបរបររកស៊ីនៅព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃ។ រាល់មន្ត្រីគ្រប់ផ្នែកទាំងអស់របស់អគ្គនាយកដ្ឋានពន្ធដារសុទ្ធសឹងតែមានជំនាញ ទេពកោសល្យ សមត្ថភាព ចំណេះដឹង ក្នុងការបំពេញនិងអនុលោមតាមការងារ ដែលអាចផ្តល់ទំនុកចិត្ត និងធានាបាននូវគុណភាពជូនទៅសាធារណៈជន និងអ្នកជាប់ពន្ធផងដែរ។ តាមរយៈអ្នកជាប់ពន្ធទាំងអស់ដែលគោរពតាមច្បាប់ពន្ធ ដែលធានាបានថាការបង់ពន្ធគឺទាន់ទៅតាមពេលវេលាកំណត់។ ការបង់ពន្ធរបស់ប្រជាពលរដ្ឋ គឺមានសារៈសំខាន់ណាស់ ដែលជាប្រភពចំណូលមួយផ្នែកដល់ប្រទេស ក្នុងការអភិវឌ្ឍប្រទេសរីកចម្រើន។ យ៉ាងណាមិញ ក៏អាចឱ្យយើងសង្កេតឃើញថាចំណូល ដែលបានមកពីការប្រមូលប៉ាតង់ជាចំណូលមួយយ៉ាងសំខាន់ក្នុងចំណោមចំណូលផ្សេងៗទៀត ដែលបានធ្វើឱ្យប្រទេសកម្ពុជាមានការកាន់តែរីកចម្រើន។

ជារួមមក ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារត្រូវបានអនុវត្តន៍និង ប្រព្រឹត្តទៅតាមច្បាប់ដោយបានចាត់ចែងយ៉ាងច្បាស់លាស់រួមទាំងប្រកបទៅដោយ តម្លាភាព ប្រសិទ្ធិភាព វិជ្ជាជីវៈ និងសីលធម៌យ៉ាងគួរឱ្យជឿជាក់ទុកចិត្ត។

# មាតិកា

ទំព័រ

អារម្ភកថា ............................................................ i

រចនាសម្ព័ន្ធ ............................................................ ii

សេចក្តីថ្លែងអំណរគុណ ............................................................ iii

អំណះអំណាង ............................................................ vi

សេចក្តីសង្ខេបនៃការស្រាវជ្រាវ ............................................................ v

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ............................................................ ១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ............................................................ ១

១. តើដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារមានលក្ខណៈដូចម្តេចខ្លះ?

២. តើពន្ធប៉ាតង់អាចបង់បាននៅពេលណា និងតាមមធ្យោបាយអ្វីខ្លះ?

១.៣ គោលបំណងនៃការស្រាវជ្រាវ ............................................................ ២

១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ............................................................ ២

១.៤.១ ទំហំដែនកំណត់ ............................................................ ២

១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ............................................................ ២

១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ............................................................ ២

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ............................................................ ៣

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ............................................................ ៣

## ជំពូកទី២
## ដំណើរការនៃការប្រមូលពន្ធប៉ាតង់

២.១ លក្ខណៈទូទៅនៃពន្ធ ............................................................ ៤

២.១.១ និយមន័យពន្ធ ............................................................ ៥

២.១.២ ប្រវត្តិនៃពន្ធ ............................................................ ៦

២.១.៣ ទ្រឹស្តីនៃពន្ធ ............................................................ ៦

២.២ ដំណើរការនៃការប្រមូលពន្ធប៉ាតង់ ............................................................ ៧

២.២.១ និយមន័យ ............................................................ ៧

២.២.២ ប្រវិត្តនៃពន្ធប៉ាតង់ ............................................................ ៨

២.២.៣ ទ្រឹស្តីនៃពន្ធប៉ាតង់ ............................................................ ១០

២.៣ កាលបរិច្ឆេទនៃការបង់ពន្ធប៉ាតង់ និងមធ្យោបាយបង់ពន្ធប៉ាតង់ ............................................................ ១១

២.៣.១ និយមន័យ ............................................................ ១១

២.៣.២ ប្រវត្តិនៃការប្រមូលពន្ធ ........................................................................................... ១១
២.៣.៣ ទ្រឹស្តីនៃការប្រមូលពន្ធ ........................................................................................... ១២

## ជំពូកទី៣
## ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ

៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ ............................................................... ១៦
៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ ............................................................... ១៦
៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅ របស់អគ្គនាយកដ្ឋានពន្ធដារ ............................... ១៦
ក.ចក្ខុវិស័យ ....................................................................................................... ១៦
ខ.បេសកកម្ម ....................................................................................................... ១៧
គ.គោលដៅ ....................................................................................................... ១៧
ឃ.គុណតម្លៃ ....................................................................................................... ១៨
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច របស់អគ្គនាយកដ្ឋានពន្ធដារ ...................... ១៩
ក. រចនាសម្ព័ន្ធគ្រប់គ្រង ............................................................................ ១៩
ខ. តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ .................................................. ២១
៣.១.៤ និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារ ............................................................... ២២
៣.២ ដំណើរការក្នុងការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ .......................................... ២២
៣.២.១ មូលហេតុនៃការប្រមូលពន្ធប៉ាតង់ ............................................................... ២២
៣.២.២ ដំណើរការនៃការចុះបញ្ជីពន្ធប៉ាតង់ ............................................................... ២៣
៣.២.៣ បែបបទនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ .................................. ២៤
៣.២.៤ ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និងកម្រិតប្រាក់ពន្ធប៉ាតង់ត្រូវបង់ និងប័ណ្ណប៉ាតង ........................................................................................ ២៥
៣.២.៥ ការឈប់ ផ្អាក និងផ្លាស់ប្តូរម្ចាស់អាជីវកម្ម ............................................................ ២៩
៣.៣ កាលបរិច្ឆេទនៃការបង់ពន្ធប៉ាតង់ និងមធ្យោបាយបង់ពន្ធប៉ាតង់ ........................................ ២៩
៣.៣.១ បែបបទនៃការបង់ពន្ធប៉ាតង់របស់ក្រុមហ៊ុន ........................................................ ២៩
៣.៣.២ កាលបរិច្ឆេទ និងមធ្យោបាយនៃការបង់ពន្ធប៉ាតង់ ................................................ ៣០
៣.៣.៣ កាតព្វកិច្ចនិងតួនាទីរបស់អ្នកជាប់ពន្ធប៉ាតង់និងក្រុមហ៊ុនដែលមានតួនាទីបង់ពន្ធប៉ាតង់... ៣១

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង ........................................ ៣៣
៤.២ ការវិភាគលើចំណុចខ្សោយ ........................................ ៣៣

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ........................................ ៣៦
៥.២ ការផ្តល់អនុសាសន៍ ........................................ ៣៧

# ជំពូកទី១
# សេចក្ដីផ្ដើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលស្ថិតនៅឧបទ្វីបឥណ្ឌូចិន ដែលបច្ចុប្បន្នកំពុងមានការអភិវឌ្ឍយ៉ាងខ្លាំងស្ទើរគ្រប់វិស័យ។ នៅក្នុងការអភិវឌ្ឍប្រទេសកម្ពុជាឲ្យមានការផ្លាស់ប្តូរនូវមុខមាត់ថ្មីបែបនេះ ក៏មានការរួមចំណែកផងដែរពីប្រជាពលរដ្ឋ និងបណ្តាលក្រុមហ៊ុនផ្សេងៗ ដែលកំពុងធ្វើសកម្មភាពជកហូតពន្ធពីអ្នកប្រើប្រាស់ចុងក្រោយយកទៅបង់ជូនរដ្ឋ ដើម្បីយកទៅផ្គត់ផ្គង់ចំណាយរបស់រាជរដ្ឋាភិបាល និងអភិវឌ្ឍន៍ផ្នែកផ្សេងៗទៀត នៅក្នុងប្រទេសឲ្យកាន់តែបន្តរីកចម្រើនទៅមុខទៀត។ ចំពោះដំណើរការ នៃច្បាប់ស្តីពីការប្រមូលពន្ធពីប្រជាពលរដ្ឋត្រូវបានធ្វើការសម្រេចចិត្តបង្កើតឡើង ដោយក្រុមប្រឹក្សាបដិវត្តន៍កម្ពុជា ដែលមានឈ្មោះថា អគ្គនាយកដ្ឋានពន្ធដារ តាមសេចក្តីសម្រេចលេខ ៤១សរ ចុះថ្ងៃទី២៤ ខែមិនា ឆ្នាំ ១៩៨១។

បច្ចុប្បន្ន ប្រទេសកម្ពុជាមានប្រភេទពន្ធអាករជាច្រើនរួមមាន អាករលើតម្លៃបន្ថែម ពន្ធលើប្រាក់បៀវត្សប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ពន្ធប៉ាតង់ ពន្ធកាត់ទុក អាករបំភ្លឺសាធារណៈ អាករស្នាក់នៅ អាករពិសេសលើទំនិញ សេវានានា និងប្រភេទពន្ធអាករជាច្រើនផ្សេងទៀត ហើយចំពោះការប្រមូលពន្ធប៉ាតង់មានការបែងចែកការប្រមូលពន្ធទៅតាមខេត្ត ខណ្ឌនីមួយៗ ទៅតាមប្រភេទនៃអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។ យោងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ១០១១ សជណពហ ចុះនៅថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩១ ស្តីពីការអនុញ្ញាតិឱ្យប្រមូលពន្ធប៉ាតង់ ឬពន្ធអាជីវកម្ម។ ពន្ធប៉ាតង់ គឺជាប្រភេទពន្ធផ្ទាល់ប្រចាំឆ្នាំ ដែលធ្វើការប្រមូលមួយដងក្នុងមួយឆ្នាំនៅដើមឆ្នាំទៅលើសហគ្រាសនិងក្រុមហ៊ុនទាំងឡាយណា ដែលប្រកបរបរអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយមើលទៅលើសកម្មភាពអាជីវកម្ម និងចំណាត់ថ្នាក់អ្នកជាប់ពន្ធ(**ពន្ធតូចពន្ធមធ្យម និងពន្ធធំ**)ផ្អែកទៅលើកម្រិតផលរបរ និង ទ្រព្យសកម្ម របស់ក្រុមហ៊ុន សហគ្រាស។

ពន្ធប៉ាតង់ គឺបានចូលរួមចំណែកក្នុងការប្រមូលប្រាក់ពន្ធ ទៅតាមទំហំរបស់បណ្តាអាជីវកម្ម ដែលមានផែនការណែនាំកិច្ចការប្រកបអាជីវកម្មឱ្យស្របទៅតាមទិសដៅអភិវឌ្ឍន៍នៃសេដ្ឋកិច្ចជាតិ ដែលបានរួមចំណែកបង្កើនចំណូលថវិការរដ្ឋ ដើម្បីបម្រើនូវសំណូមពរពីការចំណាយក្នុងកិច្ចអភិវឌ្ឍន៍ប្រទេស។ ដោយមើលឃើញពីចំណុចសំខាន់ៗដែលបានរៀបរាប់ខាងលើនេះ ទើបក្រុមនាងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទមួយស្តីពី «**ដំណើរការនៃការប្រមូលពន្ធប៉ាតង់ របស់អគ្គនាយកដ្ឋានពន្ធដារ**» យកមកធ្វើការស្រាវជ្រាវនិងចងក្រងជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីផ្តល់ភាពងាយស្រួលឲ្យបានយល់ដឹងកាន់តែច្បាស់ស្តីពី ដំណើរការ និងលក្ខណៈប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ ក្រុមយើងខ្ញុំលើកឡើងពីរចំណុចសំខាន់ៗ ដើម្បីធ្វើការបកស្រាយលម្អិតទៅលើប្រធានបទមួយនេះ។

១.តើដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារមានលក្ខណៈដូចម្តេចខ្លះ?

២.តើពន្ធប៉ាតង់អាចបង់បាននៅពេលណា និងតាមមធ្យោបាយអ្វីខ្លះ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវមួយនេះ គឺចង់បង្ហាញអំពីដំណើរនៃការប្រមូល ពន្ធប៉ាតង់ របស់ របស់អគ្គនាយកដ្ឋានពន្ធដារដោយផ្អែកទៅលើ៖

**ទ្រឹស្តីនៃដំណើរការនៃការប្រមូលពន្ធប៉ាតង់៖**

-ទ្រឹស្តីនៃដំណើរការនៃការប្រមូលពន្ធប៉ាតង់

-ប្រវត្តិនៃកាលបរិច្ឆេទ និង តួនាទីរបស់ក្រុមហ៊ុនដែលត្រូវបង់ពន្ធប៉ាតង់

-ស្រាវជ្រាវចំណុចខ្លាំង និងចំណុចខ្សោយរបស់ពន្ធដារ

-សិក្សាស្វែងយល់ទៅលើស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ

-ចក្ខុវិស័យ បេសកកម្ម គោលដៅ របស់អគ្គនាយកដ្ឋានពន្ធដារ

-លក្ខណៈសម្បត្តិរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងការប្រកាសពន្ធ

-កាតព្វកិច្ចរបស់អ្នកជាប់ពន្ធប៉ាតង់

-ការឈប់ ផ្អាក និងផ្លាស់ប្តូរម្ចាស់អាជីវកម្ម

-កម្រិត ប្រាក់ពន្ធប៉ាតង់ត្រូវបង់ និងប័ណ្ណប៉ាតង់។

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

ការសិក្សាស្រាវជ្រាវទៅលើកិច្ចការនេះ គឺសិក្សាទៅលើ«**ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ**»ដែលមានទីតាំងស្ថិតនៅលើផ្លូវ ៥២២-៥២៤ កែងមហាវិថីសហព័ន្ធរុស្សី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។យើងផ្តោតសំខាន់ទៅលើ ដំណើរការនៃការប្រមូលពន្ធ ភារកិច្ចនិងតួនាទីគណៈគ្រប់គ្រង និងព័ត៌មានទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ។ និង លេខទូរស័ព្ទទំនាក់ទំនង៖ (៨៥៥) ២៣ ៨៨៦ ៧០៨ និងសារអេឡិចត្រូនិក៖ info@tax.gov.kh។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

ដំណើរការនៃការស្រាវជ្រាវនេះ ធ្វើឡើងដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់ពីតថភាពនៃការប្រមូលពន្ធប៉ាតង់របស់គ្គនាយកដ្ឋានពន្ធដារជាក់ស្តែងក្នុងឆ្នាំ២០២៤ប៉ុណ្ណោះ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីឱ្យដំណើរការនៃការសរសេរកិច្ចការស្រាវជ្រាវសារណាទៅលើប្រធានបទស្តីពី «**ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ**» ឱ្យបានជោគជ័យក្រុមនាងខ្ញុំបានធ្វើការស្រាវជ្រាវដូចជា៖ ការប្រមូលទិន្នន័យ តាមរយៈការស្រាវជ្រាវនៅតាមបណ្ណាល័យនានា សារណារបស់រៀមច្បង ឯកសារនានាដែលក្រុមនាងខ្ញុំធ្លាប់បានសិក្សាពីមុនមក ការពិភាក្សាជាមួយសាស្ត្រាចារ្យដឹកនាំនៃកិច្ចការស្រាវជ្រាវ និង តាមគេហទំព័រវេបសាយរបស់អគ្គនាយកដ្ឋានពន្ធដារដែលស្តីអំពីការប្រមូលពន្ធប៉ាតង់ ដើម្បីមានភាពងាយស្រួលនិងជួយសម្រួលដល់ការស្រាវជ្រាវរបស់ក្រុមនាងខ្ញុំ ក្នុងការសរសេរកិច្ចការស្រាវជ្រាវឱ្យបានកាន់តែប្រសើរឡើង។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ គឺមានសារៈសំខាន់ខ្លាំងណាស់ដល់និស្សិតដើម្បីពង្រឹង និងពង្រីកនូវចំណេះដឹងឱ្យកាន់តែ មានចំណេះដឹងទូលំទូលាយ និងទទួលបាននូវចំណេះដឹងថ្មីៗ ហើយក៏អាចអភិវឌ្ឍន៍ខ្លួនបានថែមមួយកម្រិតទៀត។ លើសពីនេះទៅទៀត ធ្វើឱ្យយើងឃើញថាវាជាតម្រូវការចាំបាច់ដែល សិស្សនិស្សិតគ្រប់រូបត្រូវមានដើម្បីយល់ដឹងពីអ្វីមួយបានកាន់តែច្បាស់ និងសកម្មភាពនានាដែលកើតមាននៅក្នុងសង្គមបច្ចុប្បន្ននេះផងដែរ។

**សារៈសំខាន់នៃការសិក្សាស្រាវជ្រាវនេះបានផ្តល់ផលប្រយោជន៍ដល់ក្រុមរបស់នាងខ្ញុំដូចជា៖**

-បង្កើននូវការយល់ដឹងពីការសិក្សាស្រាវជ្រាវ បណ្តុះចំណេះដឹងថ្មីៗ រួមទាំងការស្វ័យសិក្សា

-ទទួលបាននូវបទពិសោធន៍ក្នុងការស្រាវជ្រាវ និងដោះស្រាយបញ្ហាជាក្រុម

-យល់ដឹងពីដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ

-មានទំនាក់ទំនងកាន់តែជិតស្និតក្នុងការធ្វើការងារជាក្រុម

-ស្គាល់ពីច្បាប់ពន្ធកាន់តែច្បាស់ក្នុងនាមជាប្រជាពលរដ្ឋមួយរូប។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវ គឺធ្វើឡើងដើម្បីសិក្សាស្វែងយល់ឱ្យដឹងកាន់តែយល់ច្បាស់ នូវចំណុចនីមួយៗ ដោយធ្វើការរាប់បើបញ្ចូលចំណុច ដែលមានសេចក្តីផ្តើមនៃការស្រាវជ្រាវគោលបំណងវិធីសាស្ត្រសារៈសំខាន់នៃការស្រាវជ្រាវ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ សេចក្តីសន្និដ្ឋាន អនុសាសន៍និងមានចំណុចជាច្រើនទៀត។ក្រោយពីបានសិក្សាស្រាវជ្រាវរួចមកក្រុមយើងខ្ញុំក៏បានបែងចែកជាប្រាំជំពូក ដែលបានរៀបរាប់ដូចខាងក្រោម៖

**ជំពូកទី១៖ (សេចក្តីផ្តើម)** បរិយាយសង្ខេបពីលំនាំបញ្ហា គោលបំណងមូលហេតុនៃការស្រាវជ្រាវ ចំណោទបញ្ហា ហេតុផលមួយចំនួនដែលបង្កើតឱ្យមានការសិក្សាស្រាវជ្រាវ។

**ជំពូកទី២៖ (រំលឹកទ្រឹស្តី)** បង្ហាញពីនិយមន័យ ប្រវត្តិទូទៅដែលពាក់ព័ន្ធ និងទ្រឹស្តីរបស់អ្នកប្រាជ្ញដែលពាក់ព័ន្ធនឹងការសិក្សាស្រាវជ្រាវ។

**ជំពូកទី៣៖ (លទ្ធផលនៃការស្រាវជ្រាវ)** បង្ហាញពីស្ថានភាពទូទៅនៃដំណើរការ នៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ ។

**ជំពូកទី៤៖(ការវិភាគពីចំណុចខ្លាំងនិងចំណុចខ្សោយ)** វិភាគនិងធ្វើការស្វែងយល់ពីចំណុចខ្លាំងនិងចំណុចខ្សោយរបស់ប្រធានបទដែលពាក់ព័ន្ធ។

**ជំពូកទី៥៖(សេចក្តីសន្និដ្ឋាននិងការផ្តល់អនុសាសន៍)** សន្និដ្ឋានទៅលើចំណុចទាំងអស់ដែលនៅក្នុងអត្ថបទនិងផ្តល់អនុសាសន៍ទៅលើចំណុចដែលមានកង្វះខាតដើម្បីធ្វើការកែលម្អ។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២
# ដំណើរការនៃការប្រមូលពន្ធប៉ាតង់

## ២.១ លក្ខណៈទូទៅនៃពន្ធ

### ២.១.១ និយមន័យពន្ធ

- ពន្ធ៖ គឺជាវិភាគទានលក្ខណៈកាតព្វកិច្ច (ចាប់បង្ខំ) ស្របតាមច្បាប់កំណត់ដែលអ្នកជាប់ពន្ធទាំងរូបវន្តបុគ្គល និងនីតិបុគ្គលត្រូវបង់ជូនរដ្ឋ។ ការយកពន្ធជាមធ្យោបាយជាក់ស្តែងមួយដែលរដ្ឋប្រើប្រាស់សម្រាប់បង្កើនប្រាក់ចំណូលនិងបំពេញការចំណាយរបស់រដ្ឋ។
- ពន្ធ៖ គឺជារូបធាតុនៃការប្រមូលចំណូលមួយដែលផ្សារភ្ជាប់ជាមួយនឹងសិទ្ធិអំណាចនយោបាយរបស់រដ្ឋាភិបាល។
- ពន្ធ៖ គឺជារូបភាពនៃការបែងចែកឡើងវិញនូវចំណូលជាតិដែលរដ្ឋាភិបាលបានប្រើប្រាស់ដើម្បីប្រមូលចំណូល។
- ពន្ធ៖គឺជាបន្ទុករបស់អ្នកជាប់ពន្ធទាំងអស់ចំពោះរដ្ឋាភិបាលនិងជាកាតព្វកិច្ចរបស់គ្រប់សមាសភាពដែលកំណត់ដោយច្បាប់។យោងតាមច្បាប់ស្តីពីពន្ធដារឆ្នាំ១៩៩៧ ពន្ធសំដៅដល់ពន្ធផ្ទាល់ ដែលជាប្រភេទពន្ធប្រមូលយក ដោយផ្ទាល់ពីអ្នកជាប់ពន្ធ (Taxpayer) ក្រៅពីពន្ធគយ ឬអាករដែលសំដៅដល់ពន្ធប្រយោលដែលជាប្រភេទ នៃការប្រមូលពន្ធ ដោយប្រយោល (មិនបានប្រមូលយកដោយផ្ទាល់ពីអ្នកជាប់ពន្ធ)។ ការប្រមូលពន្ធនេះ គឺជាការយកតាមតម្លៃ ទំនិញ ឬសេវា ហើយអ្នកជាប់ពន្ធគឺជាអ្នកប្រើប្រាស់ចុងក្រោយ។
- ពន្ធ៖គឺជារូបភាពទាំងឡាយណានៃការបែងចែកឡើងវិញ នូវចំណូលជាតិដែលរដ្ឋាភិបាលបានប្រើប្រាស់ ដើម្បីប្រមូលចំណូលមួយផ្នែកពីគ្រប់សមាសភាពសេដ្ឋកិច្ច មានដូចជាក្រុមហ៊ុនសហគ្រាស អាជីវកម្ម និងប្រជាពលរដ្ឋ ដើម្បីបម្រើឲ្យតម្រូវការរួមរបស់សង្គមជាតិទាំងមូល។
- ពន្ធ៖គឺជារូបធាតុនៃការប្រមូលចំណូល ដែលផ្សារភ្ជាប់ជាមួយនឹងសិទ្ធិអំណាចនយោបាយរបស់រដ្ឋាភិបាលដែលក្រឹត្យច្បាប់ជាកំណត់។
- ពន្ធ៖ គឺជាការបង់វិភាគទាននូវកាតព្វកិច្ចរបស់គ្រប់សមាសភាពសេដ្ឋកិច្ច ដែលមានរួមទាំងរូបវន្តបុគ្គល និងនីតិបុគ្គល ជូនរាជរដ្ឋាភិបាលដែលមានច្បាប់កំណត់។
- ពន្ធ៖ គឺជាកាតព្វកិច្ចបង់ជាប្រាក់ ឬវត្ថុរបស់អ្នកជាប់ពន្ធទៅរដ្ឋាភិបាលហើយអ្នកជាប់ពន្ធទាំងនោះ ទទួល តម្លៃតបស្នងពីរដ្ឋាភិបាលវិញតាមរយៈទំនិញ និងសេវាសាធារណៈ។
- ពន្ធ៖ គឺជាបន្ទុករបស់ប្រជាពលរដ្ឋបង់ចូលថវិកាជាតិ។ ប្រជាពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ[1]។
- ពន្ធ៖ គឺជាឧបករណ៍របស់រដ្ឋាភិបាលដែលបានបង្កើតឡើង ដើម្បីកៀរគរចំណូលចូលថវិការជាតិសម្រាប់ ចំណាយសាធារណៈ។សំដៅដល់ ពន្ធអាករ (ពន្ធផ្ទាល់ និងពន្ធប្រយោល)[2]។

---

[1] សៀវភៅអគ្គនាយកដ្ឋានពន្ធដារ

[2] បណ្ណាល័យវិទ្យាស្ថាន វ៉ាន់ដា

- ពន្ធ៖ គឺសំដៅដល់ពន្ធនៃអាករទាំងឡាយ។

**២.១.២ ប្រវត្តិនៃពន្ធ**

រដ្ឋខ្មែរបានចាប់កំណើតតាំងពីសតវត្សទី១នៃគ្រិស្តសករាជមកម្ល៉េះពោលគឺនៅ សម័យកាលហ្វូណន។ តាមប្រវត្តិសាស្ត្របន្តពីហ្វូណនមានសម័យកាលជាច្រើនទៀតជាអាទិ៍ ចេនឡា អង្គរ លង្វែក ឧដុង្គ និងចតុមុខ។ ការកំណត់ សម័យកាលទាំងនេះ ធ្វើឡើងដោយផ្អែកលើការផ្លាស់ប្តូររាជធានីពីកន្លែងមួយទៅកន្លែងមួយ ដែលមានរយៈពេល ប្រមាណជាង ១,៥០០ឆ្នាំ។ នៅក្នុងសម័យកាលទាំងនេះ យើងសង្កេតឃើញថា ព្រះរាជាបានប្រមូលពន្ធពីប្រជារាស្ត្រ ដោយសារព្រះអង្គបានប្រទានដីធ្លីដល់ប្រជារាស្ត្រ ដើម្បីអាចប្រកបអាជីវកម្ម ឬ កសិកម្មជាដើម។ នៅឆ្នាំ១៨៦៣ ប្រទេសបារាំងបានចូលមកធ្វើជាអាណាព្យាបាលខ្មែរ ហើយក្រោយមកបានប្រែក្លាយប្រទេសកម្ពុជាទៅ ជាទឹកដីអាណានិគមរបស់ខ្លួននាឆ្នាំ១៨៨៤ បារាំងបាននាំយកច្បាប់ និងការគ្រប់គ្រងរដ្ឋបាលមកអនុវត្តនៅក្នុង ប្រទេសកម្ពុជា ជាពិសេសវិស័យសារពើពន្ធ។ ក្រោយពេលដែលទទួលបានឯករាជ្យពីអាណានិគមនិយមបារាំងនាថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ កម្ពុជាមានភាពពិបាកក្នុងការវិលត្រឡប់ទៅរកការអនុវត្តច្បាប់ខ្មែរ បុរាណវិញពោលគឺ កម្ពុជាបានក្លាយជាប្រទេសនៃគ្រួសារប្រព័ន្ធច្បាប់រ៉ូម៉ាំង អាល្លឺម៉ង់រួចទៅហើយ។ ជាវិបាក ច្បាប់ពន្ធដារកម្ពុជា គឺជាច្បាប់ពន្ធដារដែលមានច្បាប់ឬសគល់ចេញមកពីច្បាប់បារាំង។ បច្ចុប្បន្ននេះ កម្ពុជា មានច្បាប់ពន្ធដារបែបទំនើប និងរីកចម្រើនច្រើន ឈ្មមជាអាទិ៍ ច្បាប់ស្តីពីសារពើពន្ធត្រូវបានបង្កើតឡើងនា ឆ្នាំ១៩៩៧និងបទបញ្ញត្តិផ្សេងៗទៀត ដែលបានរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងការរៀបចំបែបនេះធ្វើឡើងក្នុងគោលបំណង ដើម្បីឆ្លើយតបទៅនឹងមាត្រា៥៧នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលបានចែងថាការយកពន្ធនឹងអាចធ្វើទៅបានលុះត្រាតែមានច្បាប់អនុញ្ញាត។ ជាការពិតណាស់យើងសង្កេតឃើញរដ្ឋាភិបាលបានសាងច្បាប់ និងលិខិតបទដ្ឋានជាច្រើនប្រមូលពន្ធពីប្រជាពលរដ្ឋមានលក្ខណៈនីត្យានុកូល[3]។ ម្យ៉ាងវិញទៀតពន្ធមានគឺមានប្រវត្តិតាំងពី ៣០០០ឆ្នាំមុនគ្រិស្តសករាជទៅទៀត ដែលដំបូងនោះវាត្រូវបានគេរកឃើញនៅក្នុងប្រទេសអាស្ស៊ីបដែលមានឈ្មោះជាឡាតាំងថាTaxo។ វាសមហេតុផល ដែលប្រជាពលរដ្ឋត្រូវបង់ពន្ធ ហេតុដូច្នេះហើយបានជាចំណេរកាលក្រោយមក ប្រទេសជាច្រើននៅទូទាំងសកលលោកបានប្រើប្រាស់ប្រព័ន្ធប្រមូលប្រាក់ពីប្រជារាស្ត្រនេះ ទៅអោយអ្នកគ្រប់គ្រងប្រទេស។

**២.១.៣ ទ្រឹស្តីនៃពន្ធ**

ការប្រមូលពន្ធទៅលើពន្ធប៉ាតង់គឺ បានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនទៅដល់ប្រទេសជាតិយើងដូច្នេះហើយ យើងត្រូវតែសិក្សា និងធ្វើការស្រាវជ្រាវបន្ថែមទៅលើទ្រឹស្តីជាច្រើននៃការប្រមូលពន្ធប៉ាតង់មាននៅក្នុងសេដ្ឋកិច្ចសាធារណៈ។ រដ្ឋាភិបាលគ្រប់ជាន់លំដាប់ថ្នាក់ទាំងអស់រួមមាន (ថ្នាក់ជាតិ តំបន់ និងមូលដ្ឋាន) ចាំបាច់ត្រូវបង្កើនប្រាក់ចំណូលពីប្រភពផ្សេងៗគ្នា ដើម្បីផ្តល់ហិរញ្ញប្បទាននៅក្នុងការចំណាយលើវិស័យសាធារណៈរបស់រាជរដ្ឋាភិបាល។

យោងតាមទ្រឹស្តីរបស់ លោក អ័ដាម ស្ម៊ីធ ជាសេដ្ឋវិទូ និងទស្សនវិទូជនជាតិស្កុតឡេនដែលជាអ្នកមានទ្រព្យសម្បត្តិនៃប្រជាជាតិមួយនៅឆ្នាំ ១៧៧៦បានសរសេរថា«រឿងដូចជាការការពារប្រទេសនិង

[3] បណ្ណាល័យវិទ្យាស្ថាន វ៉ាន់ដា

ការរក្សាស្ថាប័នរដ្ឋាភិបាល» ឱ្យបានកាន់តែល្អប្រសើរជាងមុនបន្ថែមទៀតនោះ គឺជាផលប្រយោជន៍ទូទៅសម្រាប់សាធារណៈជនទាំងឡាយ ដូច្នេះហើយ បានជាមានហេតុផលដែលប្រជាជនទាំងមូលគួរតែចូលរួមចំណែកក្នុងការចំណាយលើពន្ធ។ ប្រព័ន្ធពន្ធជាឧទាហរណ៍៖ បរិមាណនៃបុគ្គលជាប់ពន្ធដែលត្រូវបង់គួរមានទំនាក់ទំនងទៅនឹងសមត្ថភាពរបស់ពួកគេក្នុងការទូទាត់ពន្ធ ដែលត្រូវនឹងលក្ខណៈវិនិច្ឆ័យសំខាន់ៗមានចំនួនបួន។ ពោលគឺពួកគេត្រូវតែសមាមាត្រទៅនឹងប្រាក់ចំណូល ឬសមត្ថភាពក្នុងការបង់ជាក់លាក់ជាជាងតាមអំពើចិត្ត ហើយត្រូវបង់តាមពេលវេលា និងតាមមធ្យោបាយងាយស្រួលដែលបានកំណត់សម្រាប់អ្នកជាប់ពន្ធ និង ការគ្រប់គ្រងនិងការប្រមូល។ នៅក្នុងអក្សរសិល្ប៍ហិរញ្ញវត្ថុសាធារណៈទំនើបសេដ្ឋកិច្ចទាំងមូលរបស់ប្រព័ន្ធពន្ធបានអភិវឌ្ឍន៍ (សេដ្ឋកិច្ចប្រព័ន្ធពន្ធដារ) ដែលត្រូវបានកំណត់សម្គាល់ថាជាការគ្រប់គ្រងរួមនៃចំណូលសាធារណៈរបស់រដ្ឋាភិបាលឬការធ្វើសមាហរណកម្មនៃចំណូល និងចំណាយសាធារណៈរបស់ក្រុមដើម្បីធ្វើសមាហរណកម្មសេដ្ឋកិច្ចឱ្យកាន់តែរីកចម្រើនពីមួយកម្រិតទៅមួយកម្រិត។ គោលនយោបាយដែលជំរុញឱ្យមានកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍន៍ និងការការពារប្រឆាំងនឹងហានិភ័យ សម្រាប់មនុស្សជំនាន់បច្ចុប្បន្ន និងអនាគត ដែលទាក់ទងទៅនឹងទ្រឹស្តីដែលមានឥទ្ធិពលគឺជាទ្រឹស្តីនៃសមត្ថភាពដែលបង្ហាញដោយ Arthur Cecil Pigou និងទ្រឹស្តីអត្ថប្រយោជន៍ដែលបង្កើតឡើងដោយ Erik Lindahl ហើយមានកំណែទម្រង់ក្រោយជាបន្តបន្ទាប់នៃទ្រឹស្តីអត្ថប្រយោជន៍ដែលគេស្គាល់ថាជាទ្រឹស្តី "ការផ្លាស់ប្តូរដោយស្ម័គ្រចិត្ត"។ នៅក្រោមទ្រឹស្តីអត្ថប្រយោជន៍ កម្រិតពន្ធត្រូវបានកំណត់ដោយស្វ័យប្រវត្តិពីព្រោះអ្នកជាប់ពន្ធបង់តាមសមាមាត្រសម្រាប់អត្ថប្រយោជន៍រដ្ឋាភិបាលដែលពួកគេនឹងទទួលបាន។ ម្យ៉ាងវិញទៅទៀតបុគ្គលដែលទទួលបានរាល់នូវអត្ថប្រយោជន៍ច្រើនបំផុតពីសេវាសាធារណៈត្រូវបង់ពន្ធច្រើនជាងគេ។

## ២.២ ដំណើរការនៃការប្រមូលពន្ធប៉ាតង់

### ២.២.១ និយមន័យ

- ដំណើរការមានន័យថា៖ គឺជាប្រាក់ដែលប្រមូលបាន ឬតម្រូវឱ្យប្រមូលតាមសហគ្រាស ក្រុមហ៊ុនម្ចាស់អាជីវកម្ម និងអង្គភាពផ្សេងៗទៅតាមកម្រិតផ្សេងៗគ្នា ឬជាប្រាក់ចំណូលពន្ធ។
- ការប្រមូល៖ គឺជាសកម្មភាព ឬដំណើរការនៃការប្រមូលអ្វីមួយ ឬន័យម្យ៉ាងទៀតក្នុងន័យហិរញ្ញវត្ថុជាការប្រមូលប្រាក់ពីប្រភពផ្សេងៗគ្នាយកមកដាក់ក្នុងប្រភពតែមួយវិញក្នុងគោលបំណងផ្សេងគ្នា។
- ពន្ធប៉ាតង់៖ គឺជាពន្ធប្រចាំឆ្នាំដែលត្រូវបានកំណត់លើសកម្មភាពអាជីវកម្មនីមួយៗរបស់អ្នកជាប់ពន្ធដោយផ្អែកទៅលើប្រភេទអ្នកជាប់ពន្ធ និងកម្រិតផលរបរ [4]។
- ពន្ធប៉ាតង់ ជាពន្ធកំណត់លើផលរបរសុបប្រចាំឆ្នាំ ដែលត្រូវបង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនាជារៀងរាល់ឆ្នាំ។ សម្រាប់សហគ្រាសឬក្រុមហ៊ុន ដែលទើបតែចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល៦ខែដើមឆ្នាំឬបង់ពន្ធប៉ាតង់ពាក់កណ្តាលឆ្នាំ ប្រសិនបើចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល៦ខែចុងឆ្នាំ។ ចំពោះអ្នកជាប់ពន្ធដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់មុខរបរអាជីវកម្មតែមួយនៅ ក្នុងខេត្ត/ក្រុងតែមួយ មិនចាំបាច់បង់ពន្ធប៉ាតង់ផ្សេងគ្នាទេ ប៉ុន្តែបើមានមុខរបរអាជីវកម្មខុសៗគ្នា ឬស្ថិតនៅក្នុងខេត្ត/ក្រុង ផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់ទៅ

[4] https://www.tax.gov.kh/u6rhf7ogbi6/gdtstream/5787a8c3-67f7-48ea-8131-698fb67d9aad

តាមមុខរបរនីមួយៗ និងទៅតាមខេត្តក្រុងដោយឡែកៗពីគ្នា។ ចំពោះអ្នកជាប់ពន្ធទាំងអស់ត្រូវតែដាក់តាំងឬព្យួរប័ណ្ណប៉ាតង់របស់ខ្លួននៅទីកន្លែងប្រកបអាជីវកម្មរបស់ខ្លួន [5]។

- ❖ ពន្ធប៉ាតង់ គឺជាពន្ធដែលម្ចាស់អាជីវកម្មឬសហគ្រាសត្រូវបង់ប្រចាំឆ្នាំ ក្នុងកំឡុងពេលចាប់ពីដើមខែមករារហូតដល់ចុងខែមីនា។ កម្រិតពន្ធប៉ាតង់ដែលត្រូវបង់ដោយម្ចាស់សហគ្រាសនីមួយៗត្រូវបានកំណត់ដោយផ្អែកទៅលើចំណាត់ថ្នាក់អ្នកជាប់ពន្ធនិងផលរបរសរុបប្រចាំឆ្នាំ[6]។
- ❖ ពន្ធប៉ាតង់ គឺជាពន្ធប្រចាំឆ្នាំដែលត្រូវបានកំណត់លើសកម្មភាពអាជីវកម្មដោយផ្អែកលើប្រភេទអ្នកជាប់ពន្ធ (Tax-payer) និងកម្រិតផលរបរ (Turnover)[7] ។
- ❖ ពន្ធប៉ាតង់ គឺជាពន្ធដែលកំណត់លើសកម្មភាពអាជីវកម្មគ្រប់ប្រភេទ ។ ពន្ធនេះប្រែប្រួលទៅតាមកម្រិតនៃផលរបរសរុបប្រចាំឆ្នាំនៃការជួញដូរនោះ ។ អាជីវករមានកាតព្វកិច្ចបង់ពន្ធលើសកម្មភាពអាជីវកម្មរបស់ខ្លួន [8]។
- ❖ ពន្ធប៉ាតង់ គឺជាពន្ធដែលត្រូវបានកំណត់ឱ្យសហគ្រាស ក្រុមហ៊ុនទាំងអស់បង់ប្រចាំឆ្នាំគឺ ដើម្បីរាប់សហគ្រាស និងក្រុមហ៊ុនទាំងនោះមានទីតាំងរដ្ឋបាលដែលសហគ្រាស និងក្រុមហ៊ុនកំពុងស្ថិតនៅ (ជាពន្ធមួយដែលរាប់ចំនួនសហគ្រាសក្រុមហ៊ុន)។ ពន្ធនេះត្រូវបានដាក់ជាប្រយោជន៍ថវិកាថ្នាក់ក្រោមជាតិ [9]។
- ❖ ពន្ធប៉ាតង់ គឺជាប្រាក់ចំណូលប្រចាំឆ្នាំ ដែលត្រូវបានគេគណនានៅដើមឆ្នាំសម្រាប់សមាសធាតុសេដ្ឋកិច្ចទាំងអស់។ ពន្ធប៉ាតង់ត្រូវបានគិតលើអាជីវកម្មតាមដានថេរ និងចល័ត រួមទាំងព្រៃឈើ ការជីកយករ៉ែ នេសាទ សំណង់ ការដឹកជញ្ជូន និងឧស្សាហកម្ម សិប្បកម្ម ពាណិជ្ជកម្ម សេវាកម្មម្ហូបអាហារ និងសេវាកម្មក្រោមអង្គភាពឯកជនឬពាក់កណ្តាលឯកជន។ ពន្ធប៉ាតង់ គឺជាប្រភេទពន្ធផ្ទាល់ ដែលត្រូវបានប្រមូលម្តងក្នុងមួយឆ្នាំនៅដើមឆ្នាំ ហើយបន្ទាប់ពីពន្ធប៉ាតង់ត្រូវបានបង់ពាណិជ្ជករ ផលិតករមានសិទ្ធិពេញលេញ និងស្របច្បាប់ដែលទទួលស្គាល់ដោយរដ្ឋាភិបាលក្នុងការប្រព្រឹត្តិសកម្មភាពអាជីវកម្មរបស់ខ្លួន [10]។

### ២.២.២ ប្រវត្តិនៃពន្ធប៉ាតង់

#### ប្រវត្តិនៃប៉ាតង់

ប្រវត្តិរបស់ពន្ធប៉ាតង់ដំបូងឡើយគឺ មានប្រភពមកពីដើមនៃគំនិតនៃពន្ធប៉ាតង់ ដែលមានការកែទម្រង់ឱ្យបានល្អប្រសើរជាងមុនគឺមិនទាន់មានភាពច្បាស់លាស់ណាមួយនៅឡើយ។ មានភ័ស្តុតាងដែលសមហេតុសមផលជាច្រើនដើម្បីណែនាំគំនិតដែលស្រដៀងទៅនឹងប្រព័ន្ធពន្ធប៉ាតង់ ហើយត្រូវបានគេយកមកប្រើនៅក្នុងចំណោមទីក្រុងក្រិកបុរាណមួយចំនួន ទោះបីជាវាត្រូវបានទទួលស្គាល់ជាទូទៅដោយអ្នក

[5] https://vannarachincom.files.wordpress.com/2014/06/e19e9fe19f80e19e9ce19e97e19f85e19e8ee19f82e19e8ee19eb6e19f86e19e9fe19f92e19e8fe19eb8e19e96e19eb8e19e96e19e93e19f92e19e92e19e94e19f89.pdf
[6] https://www.kakcent.com/business-tax/
[7] Postkhmer.com
[8] https://www.khsearch.com/qna/28546
[9] https://m.facebook.com/CamboFinance/photos/a.501529850341749/752857338542331/?type=3
[10] https://chandaracitc.weebly.com/uploads/1/3/0/1/13016555/taxation.pdf

ប្រវត្តិសាស្ត្រជាប្រព័ន្ធក្រៅផ្លូវការលើកដំបូង ដែលមានប្រភពមកពីក្រុមហ៊ុន Renaissance ដែលស្ថិតនៅប្រទេសអ៊ីតាលីក្នុងឆ្នាំ1474 ។

ពន្ធប៉ាតង់ត្រូវបានគេបកស្រាយជាភាសាអង់គ្លេស ហើយត្រូវបានគេអនុញ្ញាតជាលើកដំបូងបង្អស់នៅឆ្នាំ1449 ដោយលោក John of Utynam ជាទស្សនៈវិទូនៃពន្ធប៉ាតង់ជនជាតិអង់គ្លេសដំបូងគេបង្អស់ ដែលបានច្នៃប្រឌិតពន្ធប៉ាតង់និងត្រូវបានគេទទួលស្គាល់នៅឆ្នាំ1449 ដែលជាក្រុមហ៊ុនផលិតកញ្ចក់ដែលមានដើមកំណើត Flemish ដោយស្តេច Henry IV ។ John of Utynam ត្រូវបានផ្តល់សិទ្ធិផ្តាច់មុខរយៈពេល 20 ឆ្នាំ សម្រាប់ដំណើរការផលិតកញ្ចក់សម្រាប់អាជីវកម្មរបស់គាត់ ដែលត្រូវបានទទួលស្គាល់នៅក្នុងប្រទេសអង់គ្លេសនៅពេលនោះ។

នេះត្រូវបានសម្គាល់ថាជានៃការចាប់ផ្តើមនៃប្រពៃណីដ៏អស្ចារ្យមួយនៅក្រោម Tudors នៃការផ្តល់លិខិតប៉ាតង់ដោយម្ចាស់ក្សត្រីអង់គ្លេស។ ម្ចាស់ក្សត្រីអង់គ្លេសបានផ្តល់សិទ្ធិផ្តាច់មុខសម្រាប់ពាណិជ្ជកម្ម និងអ្នកផលិត រួមទាំងប៉ាតង់សម្រាប់ការច្នៃប្រឌិតសម្ភារៈនានា។ Elizabeth I បានផ្តល់ប៉ាតង់ចំនួនប្រហែល 50 ពីឆ្នាំ 1561 ដល់ឆ្នាំ 1590 ដែលអនុញ្ញាតឱ្យអ្នកទទួលអនុវត្តសិទ្ធិផ្តាច់មុខក្នុងការលក់ និងផលិតទំនិញ។

ការលើកលែងចំពោះការហាមឃាត់ពន្ធប៉ាតង់នេះត្រូវបានអនុញ្ញាតសម្រាប់ «គម្រោងនៃការបង្កើតថ្មី» ច្បាប់នេះត្រូវបានបញ្ចូលទៅក្នុងច្បាប់ប៉ាតង់ទីមួយរបស់ប្រទេសអង់គ្លេស ដែលលក្ខន្តិកៈនៃភាពផ្តាច់មុខក្នុងឆ្នាំ1624។ នៅក្នុងផ្នែកទី6 នៃលក្ខន្តិកៈសភាបានបញ្ចេញភាពផ្តាច់មុខទាំងអស់ដោយខុសច្បាប់លើកលែងតែរយៈពេលកំណត់នៃ14 ឆ្នាំ ឬក្រោមដែលត្រូវបានផ្តល់ឱ្យអ្នកបង្កើតពិតប្រាកដ។

នៅក្នុងរយៈពេល 200 ឆ្នាំបន្ទាប់ពីលក្ខន្តិកៈផ្តាច់មុខប្រព័ន្ធប៉ាតង់ត្រូវបានរីកចម្រើនមួយកម្រិតទៀតជាមួយមេធាវី និងចៅក្រមនៅក្នុងតុលាការ ហើយមិនមែនជាមួយនឹងច្បាប់របស់រដ្ឋាភិបាលទេ។ វាគឺនៅក្នុងរជ្ជកាលរបស់ម្ចាស់ក្សត្រី Anne ដែលលក្ខខណ្ឌនៃការផ្តល់ជំនួយត្រូវបានផ្លាស់ប្តូរ។ មន្ត្រីច្បាប់នៃអង់គ្លេសបានលើកឡើងថាលក្ខខណ្ឌនៃការផ្តល់ជំនួយមានន័យថា ប៉ាតង់ត្រូវបានទាមទារដើម្បីផ្តល់ការពិពណ៌នាជាលាយលក្ខណ៍អក្សរនៃការបង្កើតប៉ាតង់និងរបៀបដែលវាត្រូវបានគេអនុវត្ត។

នៅឆ្នាំ1718 លោក James Puckle ដែលជាអ្នកកាន់កាប់ប៉ាតង់នៃការផលិតកាំភ្លើង គឺជាអ្នកដំបូងគេដែលតម្រូវឱ្យផ្តល់ការបញ្ជាក់ទៅលើប៉ាតង់របស់លោក លើសពីនេះទៀតនៅឆ្នាំ 1785 ប៉ាតង់សម្រាប់ម៉ាស៊ីនបង្វិលដ៏ល្បីល្បាញរបស់ Arkwright បានក្លាយទៅជាមោឃៈដោយសារតែខ្វះការបញ្ជាក់គ្រប់គ្រាន់។ នេះគឺបណ្តាលមកពីប៉ាតង់មានសុពលភាពត្រឹមតែរយៈពេល 10 ឆ្នាំប៉ុណ្ណោះ។

នៅពាក់កណ្តាលសតវត្សទី 19 ពាក្យសុំប៉ាតង់មានភាពស្មុគស្មាញ ហើយថ្លៃ និងត្រូវការកំណែទម្រង់ប្រព័ន្ធប៉ាតង់ដ៏ស្មុគស្មាញនៃពាក់កណ្តាលសតវត្សទី 19 តម្រូវឱ្យប៉ាតង់ទៅមើលការិយាល័យប្រាំពីរផ្សេងគ្នា និងទទួលបានហត្ថលេខារបស់ព្រះមហាក្សត្រពីរដងដើម្បីទទួលបានប៉ាតង់បូកនិងការបង្ខិតបង្ខំឱ្យបង់ថ្លៃនៅដំណាក់កាលនីមួយៗនៃដំណើរការ។ ទោះបីជាការផ្តល់សេវាបានគ្រប់គ្រាន់ ដែលគឺជាកន្លែងដែលមានការផ្លាស់ប្តូរបច្ចេកវិទ្យាយ៉ាងខ្លាំង វាគឺជារឿងធម្មតានៅក្នុងអំឡុងពេលបដិវត្តន៍ឧស្សាហកម្មនៃ 1760-1830 នៅពាក់កណ្តាលសតវត្សទី19 ប្រព័ន្ធប៉ាតង់គឺត្រូវការកំណែទម្រង់យ៉ាងខ្លាំង ហើយនេះត្រូវបានលាតត្រដាងដោយពិព័រណ៍ដ៏អស្ចារ្យឆ្នាំ1851 ដែលបានពន្លឿនការទាមទារកំណែទម្រង់។

ច្បាប់វិសោធនកម្មទៅលើច្បាប់ប៉ាតង់ឆ្នាំ1852 នៅបន្ទាប់ពីរយៈពេលនៃកំណែទម្រង់ស្ថាប័ននៃច្បាប់វិសោធនកម្មច្បាប់ប៉ាតង់ឆ្នាំ1852 បានបង្កើតការិយាល័យប៉ាតង់សម័យទំនើបនៅខែតុលា ឆ្នាំ1852។ បានជាលទ្ធផលធ្វើឱ្យមានការផ្លាស់ប្តូរពេញលេញ នៃប្រព័ន្ធប៉ាតង់របស់ចក្រភពអង់គ្លេសពីមុនដែលគ្មានប្រសិទ្ធភាព និងចាស់កំរិល ហើយបានផ្តល់នីតិវិធីសាមញ្ញសម្រាប់ការទទួលបានប៉ាតង់។ ការិយាល័យប៉ាតង់តម្រូវឱ្យមានការពិពណ៌នាអំពីការច្នៃប្រឌិតត្រូវបានដាក់ជាមួយពាក្យសុំ និងណែនាំការបោះពុម្ពផ្សាយកម្មវិធី។ ជាងនេះទៅទៀត ប៉ាតង់ដាច់ដោយឡែកសម្រាប់ប្រទេសនីមួយៗ នៅក្នុងចក្រភពអង់គ្លេសត្រូវបានជំនួសដោយការចេញប៉ាតង់របស់ចក្រភពអង់គ្លេសតែមួយ ហើយបានកាត់បន្ថយថ្លៃនៃច្បាប់យ៉ាងសំខាន់ប្រហែលបីត្រីមាស។

ច្បាប់ប៉ាតង់ការរចនា និងម៉ាកសញ្ញាពាណិជ្ជកម្មឆ្នាំ 1883 ត្រូវបាននាំយកមកធ្វើជាការិយាល័យរបស់អគ្គនាយកដ្ឋានប៉ាតង់ និងបុគ្គលិកនៃអ្នកពិនិត្យប៉ាតង់ ដែលអាចអនុវត្តការត្រួតពិនិត្យដែលមានកម្រិតលើពាក្យសុំប៉ាតង់។ ការពិនិត្យគឺភាគច្រើនដើម្បីធានាថាការពិពណ៌នាត្រឹមត្រូវនៃការច្នៃប្រឌិតត្រូវបានផ្តល់ដោយការបញ្ជាក់ ប៉ុន្តែមិនមានការស៊ើបអង្កេតលើភាពថ្មីថ្មោងត្រូវបានអនុវត្តទេ។

ច្បាប់ប៉ាតង់ឆ្នាំ 1902បានកត់សម្គាល់នូវព្រឹត្តិការណ៍ដ៏សំខាន់មួយក្នុងការអភិវឌ្ឍន៍ប្រព័ន្ធប៉ាតង់សម័យទំនើប។ ច្បាប់នេះបានណែនាំការស៊ើបអង្កេតទៅលើភាពថ្មីថ្មោងនៃការបង្កើតមុននឹងផ្តល់សិទ្ធិសម្រាប់រាល់ការបញ្ជាក់របស់ចក្រភពអង់គ្លេស ដែលបានបោះពុម្ពផ្សាយក្នុងរយៈពេល50ឆ្នាំគិតចាប់ពីថ្ងៃដាក់ពាក្យ។ ទោះបីជាមានការកម្រិតការស៊ើបអង្កេតក៏ដោយការងារត្រៀមបន្ថែមតម្រូវឱ្យមានការរៀបចំឡើងវិញដ៏សំខាន់នៃការិយាល័យប៉ាតង់ ដែលរួមមានការជ្រើសរើសអ្នកប្រឡងបន្ថែមចំនួន 190 នាក់ដើម្បីជួយអ្នកពិនិត្យចំនួន 70 នាក់ដែលមានស្រាប់។

ច្បាប់ប៉ាតង់ឆ្នាំ1977 ច្បាប់បច្ចុប្បន្នគឺច្បាប់ប៉ាតង់នៃឆ្នាំ1977។ ច្បាប់នេះត្រូវបានបង្កើតឡើងដើម្បីសម្រួលដល់បច្ចេកវិទ្យាទំនើប និងអនុញ្ញាតឱ្យមានការសម្របខ្លួនទៅនឹងការផ្លាស់ប្តូរបច្ចេកវិទ្យានាពេលអនាគត ដូចជាភាពជឿនលឿនក្នុងឧស្សាហកម្មឱសថ។ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ1980 អាជ្ញាធរដែលបានចេញប័ណ្ណប៉ាតង់ជាតិត្រូវបានបង្កើតឡើងដូចជាការិយាល័យប៉ាតង់អឺរ៉ុប (EPO) និងការិយាល័យកម្មសិទ្ធិបញ្ញាពិភពលោក (WIPO)។ អាជ្ញាធរទាំងនេះអនុញ្ញាតឱ្យមានការដាក់ពាក្យសុំប៉ាតង់ក្នុងពេលដំណាលគ្នានៅក្នុងប្រទេសជាច្រើនពីកម្មវិធីតែមួយ[11]។

### ២.២.៣ ទ្រឹស្តីនៃពន្ធប៉ាតង់

ទ្រឹស្តីនៃពន្ធប៉ាតង់ទំនើបដែលត្រូវបានកត់ត្រាជាលើកដំបូងត្រូវបានផ្តល់ ដោយរដ្ឋទីក្រុង Florence ក្នុងឆ្នាំ1421 ដោយលោក Filippo Brunelleschi ដែលជាអ្នកល្បីល្បាញខាងវិស្វកម្មដំបូងនៃវិហារ Florence ប៉ាតង់របស់លោក Brunelleschi គឺសម្រាប់ការបង្កើតមធ្យោបាយដឹកជញ្ជូនទំនិញធ្ងន់ៗ (ជាពិសេសនោះគឺបន្ទះថ្មម៉ាបធំៗ) ឡើងតាមទន្លេ Arno សម្រាប់ការសាងសង់វិហារFlorenceនេះឡើង។ ការរចនាទូកត្រូវបានគេដាក់ឈ្មោះថា"Il Badalone" ។អ្នកដែលបានផ្តល់ជំនួយបានផ្តល់សិទ្ធិឱ្យ Brunelleschi ដកមធ្យោបាយដឹកជញ្ជូនថ្មីទាំងអស់នៅលើទន្លេ Arno សម្រាប់រយៈពេលបីឆ្នាំ។ ក្រោយមកព្រឹទ្ធសភា Venetian បានអនុម័តច្បាប់ប៉ាតង់ដំបូង ដោយណែនាំលក្ខន្តិកៈ Venetian ក្នុងឆ្នាំ1474 ដែលការពារឧបករណ៍ថ្មី និងច្នៃប្រឌិតជាថ្នូរនឹងការបង្ហាញដល់សាធារណៈរដ្ឋ Venetian។ គំនិតផ្តួចផ្តើមនេះត្រូវបានវិនិច្ឆ័យដោយអ្នក

[11] https://www.wilsongunn.com/history/history_patents.html

ប្រវត្តិសាស្ត្រថាជាលទ្ធផលនៃការប៉ុនប៉ងដើម្បីពង្រឹងសាធារណរដ្ឋ និងការចាក់បញ្ចូលគំនិតផ្តួចផ្តើម រួមទាំងការច្នៃប្រឌិតឡើងវិញនៅពេលមានការធ្លាក់ចុះនៃសេដ្ឋកិច្ច[12]។

## ២.៣ កាលបរិច្ឆេទនៃការបង់ពន្ធប៉ាតង់ និងមធ្យោបាយបង់ពន្ធប៉ាតង់

### ២.៣.១ និយមន័យ

- ក្រុមហ៊ុន គឺជា៖

  ១. ជានីតិបុគ្គល នៃនីតិឯកជន ដែលមានបេតិកភណ្ឌផ្ទាល់ខ្លួន និងមានសមត្ថភាពគតិយុត្តប្រព្រឹត្ត(ស្វែងរកប្រាក់ចំណេញ) ក្នុងនាមនិងដើម្បីប្រយោជន៍សមូហភាព។

  ២. ជាកិច្ចសន្យារវាងបុគ្គលពីរនាក់ ឬច្រើននាក់ ដែលព្រមព្រៀងគ្នា និងដាក់នូវទ្រព្យសម្បត្តិ សេវាកម្ម ចំណេះដឹង ឬសកម្មភាពផ្សេងៗ ដើម្បីប្រកបរបរអ្វីមួយក្នុងគោលបំណងស្វែងរកប្រាក់ចំណេញសម្រាប់ក្រុមខ្លួន។ ប៉ុន្តែបុគ្គលតែម្នាក់ក៏អាចបង្កើតក្រុមហ៊ុនបានដែរ ក្នុងនាមក្រុមហ៊ុនឯកត្តបុគ្គល ឬសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត។

  សហគ្រាសក្នុងនិយមន័យពន្ធដារ គឺជារូបវន្តបុគ្គលឬនីតិបុគ្គលជាប់ពន្ធ (ហៅថាអ្នកជាប់ពន្ធ) ដែលមានកាតព្វកិច្ចចុះបញ្ជីពន្ធដារឬភ្នាក់ងារកាត់ទុកដោយស្ថិតក្រោមច្បាប់ស្តីពីសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា។

  ៣. សហគ្រាសឯកបុគ្គល ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត អង្គការមិនស្វែងរកប្រាក់ចំណេញ[13]។

- តួនាទីគឺជា៖ កាតព្វកិច្ចដែលត្រូវធ្វើ ឬត្រូវទទួលខុសត្រូវ មើលថែរក្សាឲ្យបានល្អប្រសើរ។
- មធ្យោបាយគឺជា៖ដំណើរទំនងទាំងឡាយណា ដែលល្មមសមគួរសម្រាប់ធ្វើកិច្ចការឲ្យបានសម្រេចតាមបំណង៖រកមធ្យោបាយគប្បីលៃលកធ្វើកិច្ចការនេះដោយមធ្យោបាយ យ៉ាងណាឲ្យបានសម្រេចផង។
- កាលបរិច្ឆេទគឺជា៖ការកម្រិតនៃថ្ងៃខែឆ្នាំ ការកំណត់ពេលវេលាណាមួយដើម្បីធ្វើអ្វីមួយ។

### ២.៣.២ ប្រវត្តិនៃការប្រមូលពន្ធ

វិធីសាស្ត្រនៃការប្រមូលពន្ធ ដែលប្រើប្រាស់ដោយរដ្ឋាភិបាលសម័យទំនើបហាក់ដូចជាជឿនលឿន បើប្រៀបធៀបទៅនឹងប្រភេទពន្ធដ៏សម្បូរបែបដែលបានសង្កេតឃើញមានក្នុងប្រវត្តិសាស្ត្រ។ នៅខណៈពេលដែលរដ្ឋាភិបាលភាគច្រើននាពេលបច្ចុប្បន្ននេះ ប្រមូលពន្ធតាមរយៈវិធីសាស្ត្រផ្សេងៗគ្នា ក៏ដូចជាទំនាក់ទំនងនៃប្រភេទកិច្ចសន្យាផ្សេងៗគ្នា រួមមានទាំងការរៀបចំចែករំលែកដែលបែងចែកចំណូលពន្ធរវាងរដ្ឋាភិបាលនិងអ្នកប្រមូលតាមសមាមាត្រថេរ គ្រោងការណ៍ទូទាត់ដែលបានចរចាដោយផ្អែកទៅលើមូលដ្ឋានគិតពន្ធ និងការលក់ដែលទទួលបានប្រាក់ចំណូលទៅឱ្យអ្នកប្រមូល ដែលជាថ្នូរទៅនឹងការទូទាត់សាច់ប្រាក់ដែលត្រូវបានកំណត់។ អ្នកប្រមូលពន្ធ មិនតែងតែ ជាមន្ត្រីរដ្ឋាភិបាលនោះទេ។ ពួកគេជួនកាលជាបុគ្គលឯកជន ប្រមូលពន្ធក្នុងនាមជាតំណាងរបស់ រដ្ឋាភិបាលក្រោមទំនាក់ទំនងជាភ្នាក់ងារប្រមូលពន្ធ។ លើសពីនេះទៅទៀត

---

[12] https://www.wilsongunn.com/history/history_patents.html

[13] Facebook ផ្តើមសិក្សាគណនេយ្យ ថ្ងៃ ទី ៣០ខែកក្កដា ឆ្នាំ ២០១៩

ទម្រង់កិច្ចសន្យាអាចប្រែប្រួលទៅតាមប្រភេទនៃពន្ធ ឬការផ្លាស់ប្តូរតាមពេលវេលា មិនដូចការសិក្សាអំពីទម្រង់កិច្ចសន្យាក្នុងទំនាក់ទំនងឯកជននោះទេ ។

ការចាប់អារម្មណ៍របស់អ្នកសេដ្ឋកិច្ចវិទូជាមួយនឹងភាពខុសគ្នា នៃទម្រង់កិច្ចសន្យាហាក់ដូចជាត្រូវបានបង្ខាំងចំពោះអ្នក ដែលសង្កេតឃើញនៅក្នុងវិស័យឯកជន។ ឧទាហរណ៍: មានសាច់រឿងសំខាន់មួយបានលេចចេញឡើងដើម្បីពន្យល់អំពីទម្រង់កិច្ចសន្យា ដែលត្រូវបានសង្កេតឃើញថាមានទំនាក់ទំនងជាមួយភ្នាក់ងារប្រមូលពន្ធ រវាងកម្មករ និងម្ចាស់ដីនៅក្នុងការជួលកសិកម្ម ឬរវាងអ្នកគ្រប់គ្រង និងម្ចាស់ភាគហ៊ុនស្ថិតនៅក្នុងសាជីវកម្មទំនើប។ ប៉ុន្តែទំនាក់ទំនងរវាងភ្នាក់ងារប្រមូលពន្ធនៅក្នុងការប្រមូលពន្ធដែលពាក់ព័ន្ធទៅនឹងរដ្ឋាភិបាល ហើយភ្នាក់ងាររបស់ពួកគេមិនត្រូវបានទទួលការយកចិត្តទុកដាក់ដូចគ្នានោះឡើយ។ បានជាលទ្ធផលនៃភាពជឿនលឿននៅក្នុងសាច់រឿងរបស់ទីភ្នាក់ងារប្រមូលពន្ធ មិនត្រូវបានដាក់បញ្ចូលយ៉ាងពេញលេញទៅក្នុងការអភិវឌ្ឍនៃទ្រឹស្តីទូទៅ នៃកាប្រមូលពន្ធដែលអាចធ្វើការពន្យល់បានពីភាពខុសគ្នាជាប្រវត្តិសាស្ត្រនៃទម្រង់កិច្ចសន្យាដែលបានធ្វើការអង្កេតនោះទេ។ ការពន្យល់ពីមុនមក អំពីការប្រមូលពន្ធក្នុងប្រវត្តិសាស្ត្រ ជាធម្មតាបានអនុវត្តទៅលើវិធីសាស្ត្រទៅតាមកម្រិតផ្សេងៗគ្នា។ ចំពោះបញ្ហាដោយផ្តោតលើភាពខុសគ្នារវាងការយល់ច្រឡំនៃ អ្នកប្រមូលពន្ធជាសាធារណៈ និងឯកជនដោយសន្មតថាមានភាពខុសគ្នាដែលអាចមានចម្ងល់រវាងការលើកទឹកចិត្តខាងអាកប្បកិរិយារបស់ភ្នាក់ងារប្រមូលពន្ធទាំងនោះ និងការដាក់កម្រិតការវិភាគចំពោះព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជាក់លាក់។ យើងបានដាក់ស្នើសុំឲ្យមានអ្នកសេដ្ឋកិច្ចនៃការប្រមូលពន្ធដែលអាចពន្យល់យ៉ាងស៊ីសង្វាក់គ្នាអំពីការប្រែប្រួលជាបណ្តោះអាសន្ន និងជាទំហំនៅក្នុងទម្រង់កិច្ចសន្យា។បន្ទាប់មកយើងបានបង្កើតគំរូសេដ្ឋកិច្ចទូទៅ នៃការប្រមូលពន្ធដែលបញ្ជាក់ពីការចំណាយ និងអត្ថប្រយោជន៍នៃគម្រោងជំនួស ហើយកំណត់លក្ខខណ្ឌ ដែលរដ្ឋាភិបាលនឹងជ្រើសរើសទម្រង់កិច្ចសន្យាមួយលើទម្រង់ផ្សេងទៀតក្នុងការបង្កើនប្រាក់ចំណូលសុទ្ធ[14]។

**២.៣.៣ ទ្រឹស្តីនៃការប្រមូលពន្ធ**

ទ្រឹស្តីនៃការប្រមូលពន្ធ និងគោលការណ៍នៃការប្រមូលពន្ធរបស់លោក Adam Smith មានគោលការណ៍ដែលបានចែងដូចខាងក្រោម៖

គោលការណ៍នៃសមធម៌ដែលត្រូវបានគេហៅថា ជាគោលការណ៍តាមសម្ថតភាពដែលប្រជាពលរដ្ឋទាំងអស់នៃជាតិគួរតែចូលរួមចំណែកក្នុងការចំណាយរបស់រដ្ឋាភិបាល។ តាមដែលអាចធ្វើបានតាមសមាមាត្រទៅនឹងសមត្ថភាពរៀងៗខ្លួន។ ម្យ៉ាងវិញទៀត ប្រព័ន្ធពន្ធគួរតែមានលក្ខណៈបែបនេះ ដែលប្រជាពលរដ្ឋត្រូវទទួលខុសត្រូវក្នុងការបង់ពន្ធតាមសមត្ថភាពបុគ្គលក្នុងការបង់។ ដូចដែលរដ្ឋាភិបាលបានទាមទារឱ្យមានបន្ទុកពន្ធស្មើៗគ្នាសម្រាប់មនុស្សទាំងអស់ ដែលមានស្ថានភាពស្រដៀងគ្នានៅក្នុងថ្នាក់ចំណូលសេដ្ឋកិច្ចរបស់ពួកគេ។ ដូច្នេះចំនួនពន្ធត្រូវបង់ ពេលវេលានៃការទូទាត់ វិធីសាស្ត្រនៃការទូទាត់ ទីកន្លែងបង់ប្រាក់ និងសិទ្ធិអំណាចដែលត្រូវបង់ គោលការណ៍ដែលងាយស្រួល ចំពោះរាល់ពន្ធគួរតែត្រូវបង់នៅពេលនោះតាមវិធីនេះ វាទំនងជាមានភាពងាយស្រួលសម្រាប់អ្នករួមចំណែកក្នុងការបង់វា។ ពន្ធគួរតែត្រូវបានបង់តាមរបៀបដែលការទូទាត់របស់វាគួរបង្កឱ្យមានការលំបាកតិចបំផុត ឬមិនងាយស្រួលសម្រាប់អ្នកជាប់ពន្ធ។ ចំពោះគោលការណ៍របស់សេដ្ឋកិច្ច សម្រាប់ពន្ធដែលត្រូវយកមកគិតគូរទាំងការដក និងការរក្សាទុកចេញពីហោប៉ៅរបស់ប្រជាជនឱ្យ

[14]https://www.researchgate.net/publication/23637549_Tax_Collection_in_History

បានតិចតួចបំផុតតាមដែលអាចធ្វើទៅបានលើសពីអ្វី ដែលខ្លួនបានបញ្ចូលទៅក្នុងរតនាគារសាធារណៈរបស់រដ្ឋាភិបាល។ ប្រព័ន្ធពន្ធគួរតែមានលក្ខណៈសន្សំសំចៃដើម្បីដំណើរការ ហើយពន្ធគួរតែមានលក្ខណៈបែបនេះដែលតម្លៃនៃការប្រមូលរបស់វាគាត់គួរតែមានអប្បបរមា[15]។

[15]https://www.studocu.com/id/document/universitas-atma-jaya-yogyakarta/taxation-1/tax-theory-classification/27660821#:~:text=The%20tax%20system%20should%20be%20economical%20to%20operate%20and%20the,the%20cost%20of%20its%20collection

# ជំពូកទី៣
# លទ្ធផលនៃការស្រាវជ្រាវ

# ជំពូកទី៣
# ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ



រូបភាពដកស្រង់ចេញពី www.google

## ៣.១ ស្ថានភាពទូទៅនៃអគ្គនាយកដ្ឋានពន្ធដារ

### ៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ

រដ្ឋខ្មែរបានចាប់កំណើតតាំងពីសតវត្សទី១នៃគ្រឹស្តសករាជមកម្ល៉េះ ពោលគឺសម័យកាលហ្វូណន។ តាមប្រវត្តិសាស្ត្រ បន្តពីហ្វូណន មានសម័យកាល ជាច្រើនទៀតជាអាទិ៍ ចេនឡាអង្គរលង្វែក ឧដុង្គ និង ចតុមុខ មានការកំណត់ សម័យកាលទាំងនេះធ្វើឡើងដោយផ្អែកលើការផ្លាស់ប្តូររាជធានីពីមួយកន្លែងទៅមួយកន្លែង ដែលមានរយៈពេល ប្រមាណជា ១,៥០០ឆ្នាំ។ នៅក្នុងសម័យកាលទាំងនេះ យើងសង្កេតឃើញថាព្រះរាជាបានប្រមូលពន្ធពីប្រជារាស្ត្រ ដោយសារព្រះអង្គ បានប្រទានដីធ្លីដល់ប្រជារាស្ត្រដើម្បីប្រកបអាជីវកម្ម ឬកសិកម្មជាដើម។ អគ្គនាយកដ្ឋានពន្ធដារពីដំបូងឡើយមានឈ្មោះថានាយកដ្ឋានពន្ធដារដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៥៣។ ចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ ប្រព័ន្ធពន្ធដារត្រូវលុបបំបាត់ចោលទាំងស្រុងដោយរបបប្រល័យពូជសាសន៍ប៉ុលពត។ក្នុងឆ្នាំ១៩៨០ នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងវិញ។ នៅក្នុងឆ្នាំ២០០៨ នាយកដ្ឋានពន្ធដារត្រូវបានដំឡើងទៅជាអគ្គនាយកដ្ឋានពន្ធដារដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

| | | |
|---|---|---|
| -១៩៥៣ | : | នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើង |
| -១៩៧៥-១៩៧៩ | : | ប្រព័ន្ធពន្ធដារត្រូវបានលុបបំបាត់(របបប្រល័យពូជសាសន៍ ឬរបបប៉ុលពត) |
| -១៩៨០-១៩៩៣ | : | នាយកដ្ឋានពន្ធដារឧស្សាហាពាណិជ្ជក្រសួងហិរញ្ញវត្ថុ |
| -១៩៩៣-២០០៨ | : | នាយកដ្ឋានពន្ធដារ(អង្គភាពពន្ធដារ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) |
| -២០០៨ | : | ដំឡើងទៅជានាយកដ្ឋានពន្ធដារ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ |

### ៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅ របស់អគ្គនាយកដ្ឋានពន្ធដារ

#### ក.ចក្ខុវិស័យ

ចក្ខុវិស័យខាងលើបានក្លាយជាអង្គការសាធារណៈដែលគួរឱ្យទុកចិត្ត និងគោរពទទួលស្គាល់ដោយគុណភាព និងជំនាញរបស់យើងក្នុងការប្រមូលចំណូលពន្ធ ដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ចនិងនិរន្តរភាពនៃប្រទេសកម្ពុជា។

ចក្ខុវិស័យនៃយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ គឺផ្សារភ្ជាប់នឹងចក្ខុវិស័យនៃការអភិវឌ្ឍកម្ពុជាដោយផ្តោតទៅលើ ការប្រមូលចំណូលនៅក្នុងស្រុកឱ្យមានប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិ ដើម្បីឆ្លើយតប ឱ្យបានសមស្របទៅនឹងតម្រូវការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមប្រកបដោយចីរភាព។ កម្ពុជាមានចក្ខុវិស័យសម្រេច ឱ្យបាននូវឋានៈ ជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ ដោយចំណូលសម្រាប់ប្រជាជនម្នាក់ៗក្នុងមួយឆ្នាំនឹងកើនឡើងដល់ រង្វង់ ៤.០០០ ទៅ ៥.០០០ ដុល្លារអាមេរិកនៅឆ្នាំ២០៣០ តាមរយៈការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចរបស់ជាតិ ដែលមានមូលដ្ឋានរឹងមាំ និងភាពធន់ខ្ពស់សមធម៌នៃការបែងចែកផ្លែផ្កានៃកំណើនការពង្រឹងស្ថាប័នជាតិ និងប្រព័ន្ធអភិបាលកិច្ច ដើម្បីធានាបាននូវប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព និងធានាបានសមធម៌សង្គម ដែលមានបរិយាប័ន្នផ្តល់ឱកាសស្មើគ្នា និងប្រកបដោយយុត្តិធម៌។ ក្នុងន័យនេះចំណូលក្នុងស្រុករបស់កម្ពុជានឹងក្លាយជាគ្នាស់យ៉ាងសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច ការផ្តល់ការងារជូនប្រជាពលរដ្ឋ តាមរយៈការបែងចែកឡើងវិញនូវផលទុនជាតិក្នុង

ក្របខ័ណ្ឌនៃប្រព័ន្ធថវិកាជាតិដ៏សមស្របមួយ។ ម៉្យាងទៀតការកៀរគរចំណូលឱ្យអស់សក្តានុពល គឺជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបាន សម្រាប់ពង្រឹងភាពជាម្ចាស់លើការអភិវឌ្ឍប្រទេសជាតិ និងបំពេញឱ្យបានគ្រប់គ្រាន់ទៅនឹងតម្រូវការនៃចំណាយសាធារណៈចាំបាច់នានា ដើម្បីចូលរួមវិភាគទានដល់ការសម្រេចឱ្យបាននូវការអភិវឌ្ឍប្រទេសជាតិ។

**ខ.បេសកកម្ម**

អគ្គនាយកដ្ឋានពន្ធដារ មានបេសកកម្មផ្តល់នូវសេវាកម្មដែលមានគុណភាព ពង្រឹងការអនុវត្តច្បាប់និង បទប្បញ្ញត្តិស្តីពីពន្ធដារប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព សាមញ្ញភាព និងសមធម៌ ដើម្បីជំរុញ អ្នកជាប់ពន្ធឱ្យបំពេញកាតព្វកិច្ចសារពើពន្ធដោយស្ម័គ្រចិត្ត ឈានទៅសម្រេចបាននូវការប្រមូលចំណូលពន្ធដារ ប្រកបដោយចីរភាព ក្នុងគោលដៅលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

អគ្គនាយកដ្ឋានពន្ធដារ មានបេសកកម្មធ្វើឱ្យសម្រេចការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារតាមការៈ

- ផ្តល់សេវាដល់អ្នកជាប់ពន្ធរួមមានការផ្តល់ ព័ត៌មាន អប់រំ ពន្យល់ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធ ប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ។
- អនុវត្តកម្មវិធីចាប់បង្ខំ ដោយការធ្វើសវនកម្មការអនុវត្តវិធានការតឹងទារ និងអនុវត្តទោសទណ្ឌ ទៅតាមការកំណត់ នៃបទប្បញ្ញត្តិស្តីពីពន្ធដារចំពោះ អ្នកជាប់ពន្ធដែលមិនបានប្រតិបត្តិត្រឹមត្រូវ តាមច្បាប់ និងបទប្បញ្ញត្តិនានា ស្តីពីពន្ធដារ។
- ប្រមូលចំណូលពន្ធទៅតាម ការអនុវត្តឲ្យត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូលថវិកាជាតិ។
- ផ្តល់សេវា និងការអប់រំដល់អ្នកជាប់ពន្ធដើម្បីធានាបាននូវច្បាប់នានាស្តីពីពន្ធដារដែលត្រូវបានគោរព និងអនុវត្តត្រឹមត្រូវ។
- អនុវត្តកម្មវិធីចាប់បង្ខំប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ និងស្មើភាពគ្នាចំពោះអ្នកជាប់ពន្ធ ដែលមិនគោរពច្បាប់ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ។
- អនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ដើម្បីបង្កើនឱ្យបាននូវការជឿទុកចិត្ត ចំពោះរដ្ឋបាលសារពើពន្ធ។
- បន្ថយការចំណាយរបស់រដ្ឋបាលសារពើពន្ធក្នុងការរៀបចំកម្មវិធី និងកិច្ចដំណើរការរបស់ខ្លួនធ្វើឱ្យមានភាពសាមញ្ញចំពោះតម្រូវការផ្សេងៗ និងបន្ថយការចំណាយរបស់អ្នកជាប់ពន្ធ។
- បង្កើនសមត្ថភាព ចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំ ដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព។
- បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងតាមរយៈ គោលនយោបាយ កិច្ចដំណើរការការងារ និងប្រព័ន្ធការងារដែល មានភាពច្បាស់លាស់ ទំនើប និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន។

**គ.គោលដៅ**

ដើម្បីសម្រេចគោលនូវបំណង ដែលបានរៀបរាប់ខាងលើរួមទាំងយុទ្ធសាស្ត្រកៀរគរចំណូលរបស់អគ្គនាយកដ្ឋានពន្ធដាររយៈពេលមធ្យមមានគោលដៅដូចតទៅ ៖

- ប្រមូលចំណូលចរន្តសរុបធ្វើឱ្យកើនឡើងបានយ៉ាងតិចបំផុត ០,៥ ពិន្ទុភាគរយបន្ថែមលើផលធៀបរវាងចំណូលចរន្ត នឹងផលិតផលក្នុងស្រុកសរុបជារៀងរាល់ឆ្នាំដោយត្រូវកើនពី ១៥,១៨% នៅក្នុងឆ្នាំ២០១៤ ដល់ ១៧,៣៥% នៅឆ្នាំ២០១៨។
- ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ ដើម្បីរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ និងសម្រេចគោលដៅអភិវឌ្ឍន៍ជាតិដែលស្របនឹង យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ និងដើម្បីត្រៀមខ្លួនក្លាយជាប្រទេសចំណូលមធ្យម កម្រិតខ្ពស់នាពេលខាងមុខ។
- ពង្រីកនូវលំហថវិកា ដើម្បីពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុគ្រប់គ្រងបំណុលប្រកបដោយចីរភាព និងកាត់បន្ថយការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស។
- បង្កើនធនធានថវិកា សម្រាប់តម្រូវការបន្ទាន់ករណីប្រធានស័ក្តិ និងវិបត្តិផ្សេងៗ ឬតម្រូវការចំណាយចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាល នាពេលអនាគត។

**ឃ.គុណតម្លៃ**

**ការអនុវត្ត** ៖យើងអនុវត្តនីតិរដ្ឋ គាំទ្រអ្នកដែលចង់ធ្វើអ្វីដែលត្រឹមត្រូវ និងរឹងមាំជាមួយអ្នកដែលមិនបានអនុលោមតាមច្បាប់។

**វិជ្ជាជីវៈ** ៖យើងធ្វើសកម្មភាពដោយការលះបង់ និង ជំនាញដើម្បីផ្តល់នូវដំណើរការដ៏សាមញ្ញ និងមានភាពងាយស្រួល

**ប្រសិទ្ធភាព** ៖យើងប្រើប្រាស់ធនធានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។

**សុចរិតភាព** ៖យើងប្រព្រឹត្តចំពោះមនុស្សដោយយុត្តិធម៌។

**ការគោរព** ៖យើងចាត់ទុកមនុស្សដោយសេចក្តីថ្លៃថ្នូរ និងការគោរព។

**ភាពបត់បែន** ៖យើងឆ្លើយតបយ៉ាងសកម្មចំពោះបញ្ហាប្រឈម និងទាញយកអត្ថប្រយោជន៍ពីឱកាស។

### ៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច របស់អគ្គនាយកដ្ឋានពន្ធដារ

#### ក. រចនាសម្ព័ន្ធគ្រប់គ្រង



យោងតាមមាត្រា៣៨អគ្គនាយកដ្ឋានពន្ធដារមានរចនាសម្ព័ន្ធនៅថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន ដូចខាងក្រោម៖

➢ ថ្នាក់កណ្តាល

- នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
- នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក
- នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ
- នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូច និងមធ្យម
- នាយកដ្ឋានសវនកម្មសហគ្រាស
- សាលាជាតិពន្ធដារ ថ្នាក់ស្មើនាយកដ្ឋាន
- ទីចាត់ការពន្ធដាររាជធានីភ្នំពេញ ថ្នាក់ស្មើនាយកដ្ឋាន។

សាលាជាតិពន្ធដារ និងទីចាត់ការពន្ធដាររាជធានីភ្នំពេញ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាន ជាជំនួយការ។

➢ ថ្នាក់មូលដ្ឋាន

នៅខណ្ឌនានានៃរាជធានីភ្នំពេញ និងខេត្តនីមួយៗ មានសាខាពន្ធដារខណ្ឌ និងសាខាពន្ធដារខេត្ត ដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាននៅថ្នាក់កណ្តាល និងអនុប្រធានសាខាពន្ធដារមួយចំនួនមានឋានៈស្មើប្រធានការិយាល័យនៅថ្នាក់កណ្តាល ជាជំនួយការ។ នៅស្រុក ក្រុង មានការិយាល័យពន្ធដារស្រុក ក្រុង មានថ្នាក់ស្មើការិយាល័យនៃសាខាពន្ធដារខេត្ត-ខណ្ឌនិងដឹកនាំដោយប្រធានមួយរូបអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

សាខាពន្ធដារមានខណ្ឌចំនួន ៩ ស្ថិតនៅតាមខណ្ឌនៃរាជធានីនៅភ្នំពេញ និងនៅតាមបណ្តាលខេត្តចំនួន ២៤ខេត្ត

❖ សាខាពន្ធដារខណ្ឌ

១.សាខាពន្ធដារខណ្ឌ ឬស្សីកែវ
២.សាខាពន្ធដារខណ្ឌ ដូនពេញ
៣.សាខាពន្ធដារខណ្ឌ ៧មករា
៤.សាខាពន្ធដារខណ្ឌ មានជ័យ
៥.សាខាពន្ធដារខណ្ឌ ចំការមន
៦.សាខាពន្ធដារខណ្ឌ ទួលគោក
៧.សាខាពន្ធដារខណ្ឌ ដង្កោ
៨.សាខាពន្ធដារខណ្ឌ សែនសុខ

៩.សាខាពន្ធដារខណ្ឌ ពោធិសែនជ័យ

❖ សាខាពន្ធដារខេត្ត

១.សាខាពន្ធដារខេត្ត កណ្ដាល

២.សាខាពន្ធដារខេត្តកំពង់ចាម

៣.សាខាពន្ធដារខេត្ត បាត់ដំបង

៤.សាខាពន្ធដារខេត្ត ព្រៃវែង

៥.សាខាពន្ធដារខេត្ត សៀមរាប

៦.សាខាពន្ធដារខេត្ត កំពង់ធំ

៧.សាខាពន្ធដារខេត្ត តាកែវ

៨.សាខាពន្ធដារខេត្ត ស្វាយរៀង

៩.សាខាពន្ធដារខេត្ត ពោធិ៍សាត់

១០.សាខាពន្ធដារខេត្ត កំពង់ឆ្នាំង

១១.សាខាពន្ធដារខេត្ត កំពង់ស្ពឺ

១២.សាខាពន្ធដារខេត្ត កំពត

១៣.សាខាពន្ធដារខេត្ត ព្រះសីហនុ

១៤.សាខាពន្ធដារខេត្ត កោះកុង

១៥.សាខាពន្ធដារខេត្ត ព្រះវិហារ

១៦.សាខាពន្ធដារខេត្ត ក្រចេះ

១៧.សាខាពន្ធដារខេត្ត រតនគិរី

១៨.សាខាពន្ធដារខេត្ត មណ្ឌលគិរី

១៩.សាខាពន្ធដារខេត្ត បន្ទាយមានជ័យ

២០.សាខាពន្ធដារខេត្ត ស្ទឹងត្រែង

២១.សាខាពន្ធដារខេត្ត កែប

២២.សាខាពន្ធដារខេត្ត ប៉ៃលិន

២៣.សាខាពន្ធដារខេត្ត ឧត្ដរមានជ័យ

២៤.សាខាពន្ធដារខេត្ត ត្បូងឃ្មុំ។

**ខ. តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារមានតួនាទីនិងភារកិច្ចដូចតទៅ៖

- ចូលរួមរៀបចំគោលនយោបាយសារពើពន្ធ និងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- រៀបចំសេចក្ដីព្រាងច្បាប់ លិខិតបទដ្ឋានស្ដីពីពន្ធដារ កំណត់បញ្ជីឯកសារនិងលិខិតយុត្តិការនានា សម្រាប់ការគ្រប់គ្រងប្រមូលពន្ធ។
- ប្រមូលប្រាក់ពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិចុះបញ្ជីអ្នកជាប់ពន្ធ។

- ផ្តល់ការអប់រំដល់អ្នកជាប់ពន្ធអំពីកាតព្វកិច្ចសារពើពន្ធផ្តល់សេវានិងព័ត៌មានដល់អ្នកជាប់ពន្ធដើម្បីបង់ពន្ធឱ្យបានត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ។
- កសាងកម្មវិធីសវនកម្មលើអ្នកជាប់ពន្ធ។
- កំណត់មូលដ្ឋានគិតពន្ធ ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវ ចំពោះអ្នកជាប់ពន្ធស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ។
- ស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទបញ្ញត្តិស្តីពីពន្ធដារ។
- អនុវត្តវិធានការតឹងទារនិងទោសទណ្ឌតាមច្បាប់ចំពោះអ្នកជាប់ពន្ធ ដែលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិស្តីពីពន្ធដារ។
- ធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ។
- រៀបចំ និងអនុវត្តកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិនានាទាក់ទិននឹងពន្ធដារ។
- ចូលរួមរៀបចំគម្រោងថវិកាជាតិ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

### ៣.១.៤ និមិត្តសញ្ញាអគ្គនាយកដ្ឋានពន្ធដារ

## ៣.២ ដំណើរការក្នុងការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.២.១ មូលហេតុនៃការប្រមូលពន្ធប៉ាតង់

រដ្ឋាភិបាល គឺមិនមែនចេះតែមានផែនការតំឡើងពន្ធអត្រាពន្ធនិងបង្កើតច្បាប់ពន្ធថ្មីៗនោះទេ ប៉ុន្តែរដ្ឋាភិបាលនឹងពង្រីកវិសាលភាពក្នុងប្រមូលពន្ធក្នុងប្រទេស ពីព្រោះថា មានអ្នកជាប់ពន្ធភាគច្រើនមិនទាន់ដឹងពីសារៈសំខាន់នៃការបង់ពន្ធ។ នេះបើយោងតាមមន្ត្រី ជាន់ខ្ពស់នៃអគ្គនាយកដ្ឋានពន្ធដារ **លោក គង់ វិបុល អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ** បានថ្លែងក្នុងវេទិកាស្តីពីពន្ធដារ ថាគោលនយោបាយរដ្ឋាភិបាលនឹងធ្វើកំណែទម្រង់ពន្ធដារ និងពង្រីកឲ្យអស់សមត្ថភាពក្នុងការប្រមូលពន្ធ ពីព្រោះក្រុមហ៊ុនជាច្រើនមិនទាន់មកចុះបញ្ជីនៅក្នុងអគ្គនាយកដ្ឋានពន្ធដារនៅឡើយ។ មូលហេតុចម្បងតែមួយគត់ដែលអ្នកត្រូវបង់ពន្ធនោះគឺដើម្បីចិញ្ចឹមរដ្ឋរបស់អ្នកអោយដំណើរការទៅមុខ អ្នកត្រូវបង់ពន្ធ ព្រោះប្រាក់អ្នកនឹងជួយអោយរាជរដ្ឋាភិបាលអាចចំណាយទៅលើប្រាក់ខែមន្ត្រីរាជការ អាចប្រើប្រាស់នៅក្នុងវិស័យសាធារណៈដូចជា សាងសង់សាលា

រៀន មន្ទីរពេទ្យ ផ្លូវថ្នល់ រចនាសម្ព័ន្ធតាមដងផ្លូវសាធារណៈទាំងនៅក្នុងទីក្រុងតាមបណ្ដាខេត្តភូមិឃុំនិងវិស័យសន្តិសុខផងដែរ។ ក្នុងលក្ខ័ខណ្ឌដែលអ្នកគេចវេស ឬ មិនបានបំពេញកាតព្វកិច្ចនោះទេ អ្នកអាចប្រឈមមុខត្រូវពិន័យជាសាច់ប្រាក់ រហូតអាចឈានដល់ការផ្អាកឬបញ្ឈប់អាជីវកម្មក៏ដូចជាប្រឈមមុខនឹងច្បាប់ផងដែរ។

### ៣.២.២ ក្រុមហ៊ុនដែលត្រូវចុះបញ្ជីពន្ធប៉ាតង់

❖ **ការចុះបញ្ជីពន្ធដារ**

១- បុគ្គលទាំងឡាយត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីបុគ្គល នោះចាប់ផ្ដើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពីពេលទទួលបានលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាតចេញ ដោយក្រសួង ឬស្ថាប័នពាក់ព័ន្ធ។ បុគ្គលដែលជាកម្មវត្ថុនៃការចុះបញ្ជីពន្ធដារ ជាអាទិ៍មានៈ

ក. ស្ថាប័នរដ្ឋ បេសកកម្មទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស របស់រដ្ឋាភិបាលនានា និងគណបក្សនយោបាយ។

ខ. ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត សាខាក្រុមហ៊ុន បរទេស ការិយាល័យតំណាងសហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក្រុមហ៊ុនសហកម្ម សិទ្ធិមានកម្រិត សហគ្រាសសាធារណៈ សហគ្រាសរដ្ឋ និងក្រុមហ៊ុនចម្រុះរដ្ឋ។

គ. សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

ឃ. បុគ្គលដទៃទៀតដែលធ្វើសកម្មភាពអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា។

២- បុគ្គលដូចមានចែងក្នុងកថាខណ្ឌ១ នៃប្រការនេះ ត្រូវបានតម្រូវឱ្យចុះបញ្ជីពន្ធដារស្របតាមចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ឬកម្រិតផលរបរ ដូចមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិស្ដីពីពន្ធដារ និងត្រូវស្នើ សុំចុះបញ្ជីទៅតាមទ្រង់ទ្រាយតតិយុត្តនៃបុគ្គលស្នើសុំដូចខាងក្រោម

ក. បុគ្គលដូចមានចែងក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌ១ នៃប្រការនេះ ការចុះបញ្ជីពន្ធដារ ត្រូវធ្វើឡើងតាមរយៈគេហទំព័រចុះបញ្ជីអាជីវកម្មhttps://www.registrationservices.gov.khស្របទៅតាម ការកំណត់ដូចមានចែងក្នុងអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្ដីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានបុគ្គលដែលបានបំពេញតាមលក្ខខណ្ឌតម្រូវនៃគេហទំព័រចុះបញ្ជីអាជីវកម្ម នឹងទទួលបានឯកសារបញ្ជាក់ការចុះបញ្ជីពន្ធដារជាទម្រង់ឌីជីថលដែលអាចបោះពុម្ពបានតាមគេហទំព័រចុះបញ្ជីអាជីវកម្មនេះ។

ខ. បុគ្គលដូចមានចែងក្នុងវាក្យខណ្ឌ ក វាក្យខណ្ឌ គ និងវាក្យខណ្ឌ ឃ នៃកថាខណ្ឌ១ នៃប្រការនេះ ឬ បុគ្គលណាមួយដែលមានបំណងចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ ឬ មិនអាចធ្វើការចុះបញ្ជីតាមគេហទំព័រចុះបញ្ជីអាជីវកម្មបាន

ការចុះបញ្ជីពន្ធដារត្រូវធ្វើឡើងតាមរយៈការបំពេញព័ត៌មាន និងភ្ជាប់ឯកសារតម្រូវ ដូចមានកំណត់ក្នុងពាក្យស្នើសុំចុះបញ្ជីពន្ធដារនិងបច្ចុប្បន្នភាពព័ត៌មានអ្នក ជាប់ពន្ធ (ទម្រង់១០១) ដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

៣-រដ្ឋបាលសារពើពន្ធត្រូវចេញលិខិតបញ្ជាក់ការទទួលពាក្យស្នើសុំចុះបញ្ជីពន្ធដារ និងប្រាក់ពន្ធកម្រៃសេវាដោយបញ្ជាក់កាលបរិច្ឆេទ នៃការប្រគល់ទទួលបន្ទាប់ពីបានពិនិត្យឃើញថាសំណុំឯកសារស្នើសុំនោះ

ត្រឹមត្រូវ និងគ្រប់គ្រាន់។ ដោយឡែកការស្នើសុំចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធរបស់បុគ្គលដូចមានចែងក្នុងវាក្យខណ្ឌខ នៃកថាខណ្ឌ១ នៃប្រការនេះ រដ្ឋបាលសារពើពន្ធ ត្រូវបំប្លែងឯកសារ បញ្ចូលព័ត៌មានការស្នើសុំចុះបញ្ជី និង សម្របសម្រួលនៃការទូទាត់ប្រាក់ពន្ធកម្រៃសេវាចុះបញ្ជីទៅតាមគេហទំព័រចុះបញ្ជីអាជីវកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ https://www.registrationservices.gov.kh ឱ្យបានរួចរាល់និងត្រូវចេញលិខិតបញ្ជាក់ពីការទទួលពាក្យនៃការស្នើសុំចុះបញ្ជី និងប្រាក់ពន្ធ-កម្រៃសេវាចុះបញ្ជី នៅក្រោយពេលបានទទួលលិខិតជាសារអេឡិចត្រូនិកបញ្ជាក់ការទទួលពាក្យស្នើសុំពីគេហទំព័រចុះបញ្ជីអាជីវកម្ម។

**៣.២.៣ បែបបទនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ**

ពន្ធប៉ាតង់ត្រូវបានប្រមូលមួយដងក្នុងមួយឆ្នាំនៅដើមឆ្នាំចាប់ពី ថ្ងៃទី០១ ខែ០១ រហូតដល់ថ្ងៃទី៣១ ខែ០៣ នៃឆ្នាំត្រូវបង់ពន្ធ។ សហគ្រាសឬអាជីវកម្មដ្ឋានដែលបានចុះបញ្ជី ឬចាប់ផ្តើមប្រកបអាជីវកម្មក្នុង៦ខែដើមឆ្នាំត្រូវបង់ពន្ធប៉ាតង់ពេញមួយឆ្នាំ។ បើចាប់ផ្តើមចុះបញ្ជីឬ ប្រកបអាជីវកម្ម៦ខែចុងឆ្នាំត្រូវជាប់ពន្ធកន្លះឆ្នាំ។ ករណីសហគ្រាសពាណិជ្ជកម្ម ឬសេវាកម្មដែលមានសាខាលក់ទំនិញ ឬបំរើការងារដែលត្រូវបង់ប៉ាតង់តាមថ្នាក់ដូចគ្នា ផលរបរដើម្បី កំណត់ប្រាក់ពន្ធ ត្រូវបូកផលរបរបញ្ចូលគ្នា របស់សាខា និងសហគ្រាសមេដើម្បីគិតពន្ធប៉ាតង់ត្រូវបង់នៅសហគ្រាស។ រដ្ឋបាលពន្ធដារត្រូវតែចេញប័ណ្ណប៉ាតង់បន្ទាប់បន្សំជូនទៅសាខាទាំងនោះ ហើយសហគ្រាស ដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់មុខរបរតែមួយ ស្ថិតក្នុងភូមិសាស្ត្រខេត្តក្រុងតែមួយមិនចាំបាច់បង់ពន្ធ ប៉ាតង់ផ្សេងគ្នាទេ។ ក្នុងករណីមានមុខរបរផ្សេងៗគ្នា ឬមានទីតាំងស្ថិតនៅខេត្តក្រុងផ្សេងៗគ្នា ត្រូវបង់ពន្ធប៉ាតង់តាមមុខរបរនីមួយៗ និងទៅតាមខេត្តក្រុងដែលសាខា ឃ្លាំង រោងចក្រ រោងជាងនោះស្នាក់នៅ សហគ្រាសដែលមានមុខរបរច្រើនត្រូវជាប់ពន្ធប៉ាតង់ផ្សេងគ្នាតាមមុខរបរនីមួយៗ ដែលត្រូវបានកំណត់ដូចខាងក្រោម៖

បើធ្វើការបែងចែកផលរបរទៅតាមផ្នែកមុខរបរដែល ត្រូវបង់ពន្ធប៉ាតង់ផ្សេងគ្នាបានត្រូវប្រមូលផ្សេងគ្នាតាមមុខរបរហើយចំពោះមុខរបរនីមួយៗ ត្រូវចេញប័ណ្ណប៉ាតង់មួយ។ បើបែងចែកមិនបានពន្ធប៉ាតង់ត្រូវប្រមូលលើផលរបរសរុបតាមថ្នាក់ពន្ធ ប៉ាតង់របស់មុខរបរ ដែលមានផលរបរខ្ពស់បំផុត។

ជាគោលការណ៍សម្រាប់សហគ្រាស ដែលបានបង់ពន្ធប៉ាតង់ក្នុងឆ្នាំរួចហើយត្រូវតែអនុវត្តទៅតាមលក្ខខណ្ឌដូចតទៅ ប្រសិនបើក្នុងករណីផ្លាស់ប្តូរទីកន្លែងនៅខេត្តក្រុងផ្សេងឬផ្លាស់ប្តូរមុខរបរអាជីវកម្មចាត់ទុកថាទើបចាប់ផ្តើមអាជីវកម្មត្រូវបង់ពន្ធប៉ាតង់ ថ្មីលើកលែង តែរដ្ឋបាលមូលដ្ឋានទទួលស្គាល់ថាគ្រឹមែនគោលការណ៍ផ្លាស់ប្តូរជំរុញលើកទឹកចិត្តតែត្រូវសុំប្តូរប័ណ្ណប៉ាតង់។

ក្នុងករណីត្រូវប្តូរម្ចាស់ ម្ចាស់ថ្មីត្រូវបង់ពន្ធប៉ាតង់ថ្មី លើកលែងតែម្ចាស់ ថ្មីនោះជាឪពុក ឬម្តាយ ប្តី ប្រពន្ធ ស្របតាមច្បាប់ ជាអ្នកស្នងស្របច្បាប់របស់ម្ចាស់អាជីវកម្ម ប៉ុន្តែម្ចាស់ថ្មីត្រូវប្តូរប័ណ្ណប៉ាតង់ថ្មី។

ពន្ធប៉ាតង់ត្រូវបង់នៅកន្លែងសុំប្រកបអាជីវកម្ម ឬកន្លែងសុំចុះបញ្ជីសារពើពន្ធដែលជាទីកន្លែងមានស្នាក់ការសហគ្រាសតាំងនៅ។

### ៣.២.៤ ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និងកម្រិតប្រាក់ពន្ធប៉ាតង់ត្រូវបង់ និងប័ណ្ណប៉ាតង់

ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវផ្អែកលើកម្រិតផលរបរប្រចាំឆ្នាំទៅតាមវិស័យចម្បងរួមមាន វិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្មនិងពាណិជ្ជកម្ម។ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវបានចាត់ថ្នាក់ជា បី ប្រភេទ ដូចខាងក្រោម៖

១- អ្នកជាប់ពន្ធតូច គឺជាសហគ្រាសឯកបុគ្គល ឬសហគ្រាសសហកម្មសិទ្ធ ដែល៖

ក-មានផលរបរសរុបប្រចាំឆ្នាំចាប់ពី ២៥០លានរៀល ដល់ ១០០០លានរៀលសម្រាប់វិស័យកសិកម្ម សេវាកម្ម និងពាណិជ្ជកម្ម ឬ

ខ-មានផលរបរប្រចាំឆ្នាំចាប់ពី២៥០លានរៀលដល់១ ៦០០លានរៀលសម្រាប់វិស័យឧស្សាហកម្ម ឬ

គ-មានផលរបរក្នុងរយៈពេល បីខែជាប់គ្នាណាមួយ ដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្តចាប់ពី ៦០ លានរៀលឡើងទៅ ឬ

ឃ-រំពឹងថាមានផលរបរក្នុងរយៈពេល បី ខែជាប់គ្នាខាងមុខ ចាប់ពី ៦០ លានរៀលឡើងទៅ ឬ

ង-ចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងថ្លៃ ក្នុងការផ្គត់ផ្គង់ទំនិញឬសេវា រួមទាំងភាស៊ី។

២- អ្នកជាប់ពន្ធមធ្យមគឺជាបុគ្គលដែលស្ថិតក្នុងលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌខាងក្រោម៖

ក-មានផលរបរប្រចាំឆ្នាំលើសពី១ ០០០ លានរៀល ដល់ ៤ ០០០ លានរៀល សម្រាប់វិស័យកសិកម្ម

ខ-មានផលរបរប្រចាំឆ្នាំលើសពី១ ០០០ លានរៀល ដល់ ៦ ០០០លានរៀលសម្រាប់វិស័យសេវាកម្ម និងពាណិជ្ជកម្ម ឬ

គ-មានផលរបរប្រចាំឆ្នាំលើសពី១ ៦០០ លានរៀល ដល់ ៨ ០០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម ឬ

ឃ-ជាសហគ្រាសដែលបានចុះបញ្ជីជានីតិបុគ្គល ការិយាល័យតំណាង ឬ

ង-ជាស្ថាប័នរដ្ឋថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ សមាគមឬអង្គការមិនមែនរដ្ឋាភិបាលនានា ឬ គម្រោងដែលស្ថិតក្រោមស្ថាប័នទាំងនេះ ឬ

ច-ជាបេសកកម្មទូត និងកុងស៊ុលបរទេសអង្គការអន្តរជាតិនិងទីភ្នាក់ងារសហប្រតិបត្តិកាបច្ចេកទេសរបស់រដ្ឋាភិបាលនានា ឬគម្រោងដែលស្ថិតក្រោមស្ថាប័នទាំងនេះ។

៣- អ្នកជាប់ពន្ធធំ គឺជាបុគ្គលដែលស្ថិតក្នុងលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌខាងក្រោម÷

ក- មានផលរបរប្រចាំឆ្នាំលើសពី ៤ ០០០ លានរៀល សម្រាប់វិស័យកសិកម្ម ឬ

ខ- មានផលរបរប្រចាំឆ្នាំលើសពី ៦ ០០០ លានរៀល សម្រាប់វិស័យសេវាកម្មនិងពាណិជ្ជកម្ម ឬ

គ- មានផលរបរប្រចាំឆ្នាំលើសពី ៨ ០០០ លានរៀល សម្រាប់វិស័យឧស្សាហកម្ម ឬ

ឃ- ជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនពហុជាតិ សាខាក្រុមហ៊ុនបរទេស ឬ

ង- ជាសហគ្រាសដែលបានចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់។




រូបភាពនេះនិយាយពីការប្រមូលពន្ធប៉ាតង់

ដកស្រង់ចេញពី www.google

- **ការប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូចនិច**

ការរីកចម្រើនក្នុងផ្នែកបច្ចេកវិទ្យា បានធ្វើការជម្រុញឲ្យមានការរីកលូតលាស់នូវអាជីវកម្មតាមរយៈប្រព័ន្ធអនឡាញជាច្រើនវិស័យ ដូចដែលលោកអ្នកបានសង្កេតឃើញនាពេលបច្ចុប្បន្ននេះ។ ប្រជាពលរដ្ឋជាច្រើនបានចាប់ផ្តើមការប្រកបរបរអាជីវកម្មរបស់ខ្លួនតាមប្រព័ន្ធអនឡាញ ដោយហេតុថាវាមានភាពងាយស្រួលចំពោះទំនាក់ទំនង ការផ្សព្វផ្សាយផលិតផល និងការទូទាត់ប្រាក់ក៏ដូចជាការបំលាស់ទីក្នុងការធ្វើកិច្ចការងារផ្សេងៗទៀតជាដើម។ ជាមួយគ្នានេះកាលពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២០ កន្លងទៅ ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡចត្រូនិចត្រូវបានអនុម័ត ដើម្បីធ្វើការគ្រប់គ្រងទៅលើការប្រកបអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិច ឬអនឡាញ ក្នុងគោលបំណងសម្រួលនិងជម្រុញការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច ជាការពិតណាស់គ្រប់ការប្រកបអាជីវកម្មទាំងអស់គឺត្រូវមានការស្នើសុំច្បាប់អនុញ្ញាត ឬចុះបញ្ជីឲ្យបានត្រឹមត្រូវ។ ចំពោះការប្រកបអាជីវកម្មតាមអនឡាញក៏ដូចគ្នា ដោយយោងទៅលើបញ្ញត្តិច្បាប់ជាធរមាន ការប្រកបអាជីវកម្មតាមអនឡាញនេះវាពាក់ព័ន្ធជាមួយនឹងស្ថាប័នសំខាន់ៗមិនខុសពីការប្រកបអាជីវកម្មខាងក្រៅទូទៅនោះទេ ដូចជាក្រសួង ឬមន្ទីរពាណិជ្ជកម្ម អង្គភាពពន្ធដារនៅពេលខាងមុខនេះច្បាប់នឹងត្រូវអនុម័តបន្ថែមទៀតដែលការប្រកបអាជីវកម្មបែបនេះ និងពាក់ព័ន្ធជាមួយនឹងក្រសួងប្រៃសណីយ៍ព្រមទាំងទូរគមនាគមន៍ផងដែរ។ អេឡិចត្រូនិចទាំងក្នុងនិងក្រៅប្រទេស ផ្តល់នូវទំនុកចិត្ត និងការការពារដល់អ្នកប្រើប្រាស់ជាដើម។

ដើម្បីត្រៀមខ្លួន និងបំពេញនូវលក្ខខណ្ឌផ្សេងៗក្នុងការធ្វើអាជីវកម្មឬពាណិជ្ជកម្មតាមរយៈប្រព័ន្ធអេឡិចត្រូនិចរបស់លោកអ្នកឱ្យមានភាពត្រឹមត្រូវស្របទៅតាមនីតិវិធីច្បាប់ គ្រប់ការប្រកបអាជីវកម្មទាំងអស់ គឺត្រូវមានការស្នើសុំច្បាប់អនុញ្ញាត ឬចុះបញ្ជីឲ្យបានត្រឹមត្រូវ ចំពោះអ្នកប្រកបអាជីវកម្មតាមអនឡាញដែលមានចំណូលផលរបរប្រចាំឆ្នាំចាប់ពី ២៥០លានរៀលឡើងទៅ។ នៅពេលលោកអ្នកធ្វើការប្រកបអាជីវកម្ម អនុវត្តន៍ស្របទៅតាមច្បាប់ វានឹងធ្វើឲ្យអាជីវកម្មរបស់លោកអ្នកកាន់តែទទួលបាននូវទំនុកចិត្ត ការទាក់ទាញនូវអតិថិជន និងការប្រកួតប្រជែងនៅលើទីផ្សារដោយស្មើភាព។ ក្នុងករណីដែលលោកអ្នកខកខានមិនបានបំពេញនូវកាតព្វកិច្ចចុះបញ្ជីនោះទេ ការប្រកបអាជីវកម្មរបស់លោកអ្នកគឺប្រព្រឹត្តទៅដោយខុសច្បាប់ ដែលអាចធ្វើឲ្យលោកអ្នកប្រឈមជាមួយនឹងការផាកពិន័យនៅពេលដែលការអនុវត្តច្បាប់ត្រូវបានរឹតបណ្តឹងនាពេលខាងមុខ។ ដូច្នេះលោកអ្នកគួរត្រៀមខ្លួនឲ្យបានរួចរាល់ សម្រាប់អាជីវកម្មរបស់លោកអ្នក ដើម្បីកាត់បន្ថយនូវហានិភ័យ និងផ្តល់ជាមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការពង្រីកអាជីវកម្មឆ្ពោះទៅមុខ។ លោកអ្នកត្រូវរៀបចំបំពេញបែបបទក្នុងការចុះបញ្ជីអាជីវកម្មឲ្យបានឆាប់រហ័សបំផុត និងស្វែងយល់ពីកាតព្វកិច្ចនានាដែលពាក់ព័ន្ធជាពិសេសគឺកាតព្វកិច្ចសារពើពន្ធនៅអង្គភាពពន្ធដារ។

**+កម្រិតប្រាក់ពន្ធប៉ាតង់ត្រូវបង់ និងប័ណ្ណប៉ាតង់**

ប្រាក់ពន្ធប៉ាតង់ត្រូវបានកំណត់ដូចខាងក្រោម៖

១- ចំពោះអ្នកប្រកបអាជីវកម្មតាមអនឡាញដែលមានចំណូលផលរបរប្រចាំឆ្នាំ ចាប់ពី ២៥០-១ ០០០លានរៀលអ្នកជាប់ពន្ធតូច ត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន **៤០០ ០០០** រៀល។

២- ចំពោះអ្នកជាប់ពន្ធមធ្យមដែលមានចំណូលផលរបរប្រចាំឆ្នាំ ចាប់ពី ១ ០០០-៦ ០០០ លានរៀលអ្នកជាប់ពន្ធមធ្យម ត្រូវបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន **១ ២០០ ០០០** រៀល។

៣- ចំពោះអ្នកជាប់ពន្ធធំដែលមានចំណូលផលរបរប្រចាំឆ្នាំអ្នកជាប់ពន្ធធំលើសពី ៦០០០លានរៀលអ្នកជាប់ពន្ធធំ ត្រូវបង់÷

ក-ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន **៣ ០០០ ០០០** រៀល។

ខ-ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន **៥ ០០០ ០០០** រៀលក្នុងករណីដែលមានផលរបរលើសពី **១០ ០០០** លានរៀល។



៤-អ្នកជាប់ពន្ធដូចមានចែងក្នុងកថាខណ្ឌទី១ កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃមាត្រានេះ ដែលចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល៦ ខែចុងឆ្នាំត្រូវបង់ប៉ាតង់ចំនួន ពាក់កណ្តាលនៃប៉ាតង់ប្រចាំឆ្នាំ។

អ្នកជាប់ពន្ធដែលមានទីកន្លែងអាជីវកម្មជាគោលដើម ទីចាត់ការសហគ្រាស សាខា ឃ្លាំង រោងចក្រ រោងជាងសម្រាប់សកម្មភាពអាជីវកម្មតែមួយ ដែលស្ថិតនៅតាមរាជធានីខេត្តផ្សេងៗគ្នាតម្រូវឱ្យបង់ពន្ធប៉ាតង់អប្បបរមាសម្រាប់ប្រភេទអ្នកជាប់ពន្ធនីមួយៗនៅតាមរាជធានី-ខេត្តនិងកន្លែងផ្សេងទៀតដែលអាជីវកម្មនោះស្ថិតនៅ។

ប័ណ្ណពន្ធប៉ាតង់ មានតម្លៃតែចំពោះអ្នកជាប់ពន្ធដែលមានឈ្មោះក្នុងប័ណ្ណពន្ធប៉ាតង់តែប៉ុណ្ណោះករណីមានការផ្លាស់ប្តូរទីកន្លែងទៅរាជធានី-ខេត្តផ្សេង ឬផ្លាស់ប្តូរមុខរបរអាជីវកម្មថ្មី ត្រូវបង់ប្រាក់ពន្ធប៉ាតង់ថ្មីម្តងទៀត។

ក្នុងការចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬការស្ទៀបស្ទង់តម្លៃក្នុងការផ្គត់ផ្គង់ទំនិញឬសេវា អ្នកជាប់ពន្ធត្រូវតែមានប័ណ្ណពន្ធប៉ាតង់ ដែលបញ្ជាក់ពីសកម្មភាពអាជីវកម្មរបស់ខ្លួនស្របតាមកម្មវត្ថុ នៃការដេញថ្លៃពីព្រោះជាតម្លៃក្នុងការផ្គត់ផ្គង់ទំនិញ ឬសេវាទាំងនោះ។

អ្នកជាប់ពន្ធ ត្រូវមានកាតព្វកិច្ចដាក់តាំងបង្ហាញប័ណ្ណពន្ធប៉ាតង់ដែលមានសុពលភាពនៅតាមទីតាំងប្រកបអាជីវកម្មរបស់ខ្លួន។ ក្នុងករណីអ្នកជាប់ពន្ធមិនបានដាក់តាំងបង្ហាញប័ណ្ណពន្ធប៉ាតង់ ត្រូវចាត់ទុកថាបានប្រព្រឹត្តអំពើ រាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ស្របតាមមាត្រា ១២៨ និងមាត្រា ១៣៣ នៃច្បាប់ស្តីពីសារពើពន្ធ។


ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ប័ណ្ណពន្ធប៉ាតង់ ឆ្នាំ ២០២០
អ្នកជាប់ពន្ធមធ្យម

PATENT TAX 2020
Medium Taxpayer
Tax Identification Number (TIN) :
Company's name :
Registered at : General Department of Taxation Under : Tuol Kouk Tax Branch
Main business activity : Import Export (Cosmetics)
Form of enterprise : Private limited company
Owner/Representative's name : Nationality : Cambodian

Phnom Penh, 11 August 2020

រូបភាពប្រភពពី google.com

### ៣.២.៥ ការឈប់ ផ្អាក និងផ្លាស់ប្តូរម្ចាស់អាជីវកម្ម

❖ យោងតាមប្រកាស ៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**១- សហគ្រាសដែលស្នើសុំឈប់ ឬផ្អាកអាជីវកម្ម នៅក្នុងឆ្នាំជាប់ពន្ធណាមួយ៖**

ក-តម្រូវឱ្យបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចរន្តពាក់កណ្តាល ប្រសិនបើដាក់ពាក្យសុំឈប់ ឬក៏ផ្អាកអាជីវកម្មក្នុងអំឡុង ៦ខែដើមឆ្នាំនៃឆ្នាំចរន្ត។

ខ-តម្រូវឱ្យបង់ពន្ធប៉ាតង់ប្រចាំឆ្នាំចរន្តពេញមួយឆ្នាំ ប្រសិនបើដាក់ពាក្យសុំឈប់ ឬក៏ផ្អាកអាជីវកម្មនៅក្នុង អំឡុង ៦ខែចុងឆ្នាំនៃឆ្នាំចរន្ត។ ប្រាក់ពន្ធប៉ាតង់ដែលបានបង់រួចហើយ មិនត្រូវបានបង្វិលសងវិញទេ។

**២-ចំពោះអាជីវកម្មដែលផ្លាស់ប្តូរម្ចាស់ បើម្ចាស់ចាស់បានបង់ពន្ធប៉ាតង់ហើយ ម្ចាស់ថ្មីមិនបាច់បង់ពន្ធប៉ាតង់ជាថ្មីទៀតទេ ប្រសិនបើមានគ្រប់លក្ខណៈពីរខាងក្រោមនេះ៖**

ក-មិនផ្លាស់ប្តូរសកម្មភាពអាជីវកម្ម។

ខ-ម្ចាស់ថ្មីជា ឪពុក ម្តាយ ប្តី ប្រពន្ធ កូន ឬអ្នកស្នងដោយស្របច្បាប់ពីម្ចាស់អាជីវកម្មចាស់។

## ៣.៣ កាលបរិច្ឆេទនៃការបង់ពន្ធប៉ាតង់ និង មធ្យោបាយបង់ពន្ធប៉ាតង់

### ៣.៣.១ បែបបទនៃការបង់ពន្ធប៉ាតង់របស់ក្រុមហ៊ុន

បែបបទនៃការបង់ពន្ធប៉ាតង់ ត្រូវបានកំណត់ដូចខាងក្រោម÷

១- អ្នកជាប់ពន្ធដែលមានសកម្មភាពអាជីវកម្មច្រើន ត្រូវបង់ពន្ធប៉ាតង់ផ្សេងគ្នាទៅតាមសកម្មភាពអាជីវកម្មនីមួយៗ។

**ឧទាហរណ៍៖** អ្នកជាប់ពន្ធម្នាក់ដែលមានសកម្មភាពអាជីវកម្មនីហរណ៍ អាហរណ៍ ដឹកជញ្ជូន និងសណ្ឋាគារ ត្រូវបង់ពន្ធប៉ាតង់សម្រាប់ ៣ សកម្មភាពអាជីវកម្មផ្សេងគ្នា។

២-សកម្មភាពជាឧបសម្ព័ន្ធនានានៃសកម្មភាពអាជីវកម្មត្រូវបានចាត់ទុកថាជាសកម្មភាពអាជីវកម្មតែមួយ។

**ឧទាហរណ៍ទី១÷** សណ្ឋាគារមួយដែលមានក្លឹបកម្សាន្ត ភោជនីយដ្ឋាន កន្លែងម៉ាស្សា ក្លឹបហាត់ប្រាណ ឬ សកម្មភាពដទៃដែលជាឧបសម្ព័ន្ធនៃសកម្មភាពសណ្ឋាគារដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់អ្នកជាប់ពន្ធតែមួយ និងស្ថិតក្នុងទីតាំងរួមជាមួយសណ្ឋាគារ ត្រូវបង់ពន្ធប៉ាតង់តែមួយ។

**ឧទាហរណ៍ទី២÷** សហគ្រាសមួយធ្វើការប្រកបអាជីវកម្ម ទិញ-លក់កុំព្យូទ័រ កម្មវិធីកុំព្យូទ័រ ឧបករណ៍លេងហ្គេម ទូរស័ព្ទដៃ ឧបករណ៍ទូរគមនាគមន៍ផ្សេងៗ វិទ្យុ ទូរទស្សន៍ ម៉ាស៊ីនចាក់ និងថតស៊ីឌី ឌីវីឌី ឧបករណ៍បំពងសំឡេង ដែលអាជីវកម្មនេះស្ថិតនៅក្នុងចង្កោមសកម្មភាពអាជីវកម្ម "ទិញ-លក់កុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិក" តែមួយ ហើយស្ថិត នៅក្រោមការគ្រប់គ្រងផ្ទាល់របស់អ្នកជាប់ពន្ធតែមួយ និងស្ថិតក្នុងទីតាំងប្រកបអាជីវកម្មតែមួយ ត្រូវបង់ពន្ធប៉ាតង់តែមួយ។

៣-អ្នកជាប់ពន្ធ ដែលមានទីកន្លែងអាជីវកម្មជាគោលដើម ទីចាត់ការសហគ្រាស សាខា ឃ្លាំង រោងចក្រ និងរោងជាងសម្រាប់សកម្មភាពមួយនៅក្នុងរាជធានី-ខេត្តតែមួយ ត្រូវបង់ពន្ធប៉ាតង់តែមួយ។

៤-អ្នកជាប់ពន្ធ ដែលមានសកម្មភាពអាជីវកម្មនៅក្នុងរាជធានី-ខេត្តផ្សេងៗគ្នា ត្រូវតែបង់ពន្ធប៉ាតង់ទៅតាមរាជធានី-ខេត្តដែលអាជីវកម្មនោះស្ថិតនៅ។

### ៣.៣.២ កាលបរិច្ឆេទ និងមធ្យោបាយនៃការបង់ពន្ធប៉ាតង់

❖ **កាលបរិច្ឆេទបង់ពន្ធប៉ាតង់**

ពន្ធប៉ាតង់គឺជាប្រភេទពន្ធមួយ ដែលមានកាលបរិច្ឆេទក្នុងការបង់ពន្ធច្បាស់លាស់ យោងតាមប្រកាសលេខ ១៩៣ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធាន និងនីតិវិធីគ្រប់គ្រងប្រមូលពន្ធប៉ាតង់។ពន្ធប៉ាតង់ ត្រូវបង់ក្នុងអំឡុងពេលចាប់ពីថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣១ ខែមីនា ជារៀងរាល់ឆ្នាំ។ ពន្ធប៉ាតង់ ត្រូវបង់នៅរដ្ឋបាលសារពើពន្ធដែលអ្នកជាប់ពន្ធមានទីកន្លែងប្រកបអាជីវកម្មពិតប្រាកដ។

អ្នកជាប់ពន្ធដែលចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល ៦ខែដើមឆ្នាំ ត្រូវបង់ប្រាក់ពន្ធប៉ាតង់ពេញមួយឆ្នាំ ប៉ុន្តែ ប្រសិនបើចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល ៦ខែចុងឆ្នាំអ្នកជាប់ពន្ធត្រូវបង់ប្រាក់ពន្ធប៉ាតង់ពាក់កណ្តាល។

❖ **មធ្យោបាយនៃការបង់ពន្ធប៉ាតង់**

ការបង់ពន្ធប៉ាតង់របស់ក្រុមហ៊ុនអាចបង់បានតាមមធ្យោបាយមួយចំនួនដូចជា៖

១. តាមរយៈប្រព័ន្ធបង់ពន្ធតាមអនឡាញ E-Payment

២. បណ្តាធនាគារជាច្រើន ដែលជាដៃគូរបស់អគ្គនាយកដ្ឋានពន្ធដារដូចជា៖ កាណាឌីយ៉ា អេស៊ីលីដា វឌ្ឍនៈ កម្ពុជាសាធារណៈ ជេត្រាស់ រ៉ូយ៉ាល់ ស្ថាបនា អេប៊ីអេ ប្រៃសណីយ៍កម្ពុជា ក.អ និងធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា។




រូបភាពដកស្រង់ចេញពី www.google

### ៣.៣.៣ ភាតព្វកិច្ចរបស់អ្នកជាប់ពន្ធប៉ាតង់ និង ក្រុមហ៊ុនដែលមានតួនាទីបង់ពន្ធប៉ាតង់

អ្នកជាប់ពន្ធ សំដៅទៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលមានកាតព្វកិច្ចចុះបញ្ជីពន្ធដារ ដាក់លិខិតប្រកាសពន្ធ បង់ពន្ធនិងគោរពទៅតាមនីតិវិធីពន្ធដារនានា ដែលបានប្រកាសដោយអគ្គនាយកដ្ឋានពន្ធដារ។ល។ ចំណូលរបស់អ្នកបង់ពន្ធត្រូវបាន គេរាប់បញ្ចូលជាផ្នែកមួយដ៏សំខាន់ក្នុងការជំរុញឱ្យកំណើនសេដ្ឋកិច្ចប្រទេសជាតិ។ បើយោងទៅតាម ប្រកាសថ្មីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ០០៩ ដែលមានប្រសិទ្ធិភាពពីថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ មកបានធ្វើការកែសម្រួល និងការបែងចែងប្រភេទនៃអ្នកជាប់ពន្ធក្នុងប្រទេសកម្ពុជា ជា៣ប្រភេទគឺ អ្នកជាប់ពន្ធតូច អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ។ ការកែសម្រួលថ្មីនេះ មានលក្ខណៈលម្អិត និងច្បាស់លាស់ជាងមុនដែលមានការបែងចែកចំណាត់ថ្នាក់អ្នកចុះបញ្ជីពន្ធ យោងទៅតាមផលរបរប្រចាំឆ្នាំរបស់ពួកគេតាមវិស័យចម្បងៗនានា និងមិនមានការប្រែប្រួលតាមទម្រង់អាជីវកម្មដូចពីមុនទេ។ ករណី ដែលអ្នកចុះបញ្ជីពន្ធមិនមានការបង្ហាញព័ត៌មានច្បាស់លាស់អំពីផលរបរប្រចាំឆ្នាំ ការបែងចែងចំណាត់ថ្នាក់ជាបន្តបន្ទាប់ និងត្រូវមើលទៅលើទំហំទ្រព្យសកម្ម ដែលអាជីវកម្មនោះមានផ្ទាល់តែម្តង។ អ្នកជាប់ពន្ធមានកាតព្វកិច្ចដូចខាងក្រោម៖

- ចុះឈ្មោះក្នុងបញ្ជីរបស់រដ្ឋបាលសារពើពន្ធ។
- ដាក់លិខិតប្រកាសសារពើពន្ធ និងផ្តល់ព័ត៌មានតាមការតម្រូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារ។
- បង់ពន្ធតាមកាលបរិច្ឆេទកំណត់។
- កាន់កាប់ថែរក្សា និងត្រូវបង្ហាញបញ្ជីលិខិតយុត្តិការ និងឯកសារផ្សេងៗដល់រដ្ឋបាលសារពើពន្ធ។
- បង្ហាញខ្លួនចំពោះរដ្ឋបាលសារពើពន្ធតាមកាលបរិច្ឆេទ ដែលមានចុះនៅក្នុងលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ។
- បង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និង ការប្រាក់ផ្សេងៗ ដែលរដ្ឋបាលសារពើពន្ធបាន កំណត់ទៅតាមកាលបរិច្ឆេទដូចមានចែងនៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ឬ ដែលរដ្ឋបាលសារពើពន្ធបានជូនដំណឹងជាលាយលក្ខណ៍អក្សរ។
- ត្រូវមានភាពស្មោះត្រង់ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ។
- ត្រូវមានកិច្ចសហប្រតិបត្តិការជាមួយរដ្ឋបាលសារពើពន្ធក្នុងការបំពេញកាតព្វកិច្ច។

**យោងតាមមាត្រ១១០នៃច្បាប់សារពើពន្ធក្រុមហ៊ុនដែលជាប់ពន្ធតាមរបបស្វ័យប្រកាសមួយចំនួនត្រូវបានលើកលែងក្នុងការបង់ប្រាក់ពន្ធ**

ពន្ធប៉ាតង់ត្រូវបានលើកលែងដូចខាងក្រោម៖

១- ស្ថាប័នរដ្ឋ បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលដទៃទៀត។

២- សកម្មភាពរបស់អង្គការណាមួយដែលត្រូវបានរៀបចំឡើង និងបានដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬអប់រំ និងគ្មានចំណែកណាមួយនៃទ្រព្យឬ ប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាផលប្រយោជន៍ឯកជន។

៣- គ្រប់សកម្មភាពអាជីវកម្ម ដែលមានផលរបរសរុបប្រចាំឆ្នាំក្រោមកម្រិតផលរបរអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដូចមានកំណត់ក្នុងមាត្រា៦នៃច្បាប់នេះ។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវអស់រយៈពេលជាច្រើនខែកន្លងមកនេះ ក្រុមយើងខ្ញុំបានប្រមូលផ្តុំនូវទិន្នន័យ និងព័ត៌មានសំខាន់ៗជាច្រើន ដើម្បីទុកធ្វើជាទុនក្នុងការវិភាគ ស្ទាបស្ទង់ វាស់វែង វាយតម្លៃ សិក្សាស្វែងយល់អំពីដំណើរការនៃ ការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារឱ្យបានកាន់តែស៊ីជម្រៅជាងមុនបន្ថែមទៀត។ អំឡុងពេលនៃការសិក្សាស្រាវជ្រាវនេះដែរក្រុមយើងខ្ញុំបានសង្កេតឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយរបស់អគ្គនាយកដ្ឋានពន្ធដារទៅលើដំណើរការនៃការប្រមូលពន្ធប៉ាតង់ ដែលមានដូចខាងក្រោមៈ

## ៤.១ ការវិភាគលើចំណុចខ្លាំង

- អគ្គនាយកដ្ឋានពន្ធដារ ជាអង្គភាពសាធារណៈដែលត្រូវបានជឿជាក់គោរព និងទទួលស្គាល់លើគុណភាព និងជំនាញក្នុងការប្រមូលចំណូលចូលពន្ធដារ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចប្រទេស និងការអភិវឌ្ឍប្រកបដោយចីរភាព។
- អគ្គនាយកដ្ឋានពន្ធដារផ្តល់នូវសេវា ដែលមានគុណភាព តម្លាភាព និងការគោរពប្រកបដោយវិជ្ជាជីវៈ និងពង្រឹងនូវការអនុវត្តច្បាប់ ចំពោះអ្នកជាប់ពន្ធទាំងអស់ឈានទៅរកការសម្រេចបាននូវការអភិវឌ្ឍ និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។
- អគ្គនាយកដ្ឋានពន្ធដារមានផែនការតំរឡើងអត្រាពន្ធនិងបង្កើតច្បាប់ពន្ធថ្មីៗ និងពង្រីកវិសាលភាពពន្ធដោយហ្មត់ចត់
- ប្រាក់ចំណូលដែលប្រមូលបានមកពីការបង់ពន្ធរបស់ប្រជាពលរដ្ឋ ជួយឱ្យរាជរដ្ឋាភិបាលយកទៅចំណាយលើ ប្រាក់បៀវត្សមន្ត្រីរាជការព្រមទាំងប្រើប្រាស់នៅក្នុងវិស័យសារជារណៈក្នុងគោលបំណងធ្វើការអភិវឌ្ឍន៍ប្រទេសឱ្យមានការរីកចម្រើន។
- អគ្គនាយកដ្ឋានពន្ធដារមានការកំណត់ពេលវេលាយ៉ាងច្បាស់លាស់នៅក្នុងការបង់ពន្ធទៅដល់អ្នកជាប់ពន្ធទាំងអស់ឱ្យអនុវត្តតាមយ៉ាងតឹងរឹងក្នុងករណីដែលអ្នកជាប់ពន្ធមិនបានបង់ពន្ធតាមកាលកំណត់នោះនឹងត្រូវពិន័យជាសាច់ប្រាក់ ឬរហូតឈានដល់ការផ្អាក ឬបិទអាជីវកម្មផងក៏មាន។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ជាធម្មតាអង្គភាពនីមួយៗ តែងតែមានចំណុចមិនល្អរៀងៗខ្លួន យ៉ាងណាមិញជាក់ស្តែងយើងឃើញថា អគ្គនាយកដ្ឋានពន្ធដារកម្ពុជា ក៏នៅមានចំណុចខ្វះខាតបន្តិចបន្តួចផងៗ ដោយមើលឃើញពីចំណុចខ្វះចន្លោះបន្តិចបន្តួច នាំឱ្យលេចឡើងនូវចំណុចខ្សោយដូចជា៖

- កង្វះមន្ត្រីពន្ធដារនៅមានការខ្វះខាតមួយចំនួនក្នុងការផ្តល់សេវាជូនដល់អ្នកជាប់ពន្ធ ឬទៅដល់ម្ចាស់អាជីវកម្មដែលត្រូវមកបង់ពន្ធ និងការបំពេញលិខិតស្នាមផ្សេងៗនៅមានការរង់ចាំយូរក្នុងការទទួលសេវាកម្ម។
- នៅមានក្រុមហ៊ុន សហគ្រាស និងអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិចមួយចំនួនមិនទាន់មកចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារនៅឡើយ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវ និងវិភាគទៅលើប្រធានបទ "**ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ**" រួចមកក្រុមរបស់នាងខ្ញុំអាចយល់បានថាដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកពន្ធដារមានដំណើរការ បែបបទ ទម្រង់ ការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធ កម្រិតប្រាក់ពន្ធប៉ាតង់ត្រូវបង់ តួនាទីភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធប៉ាតង់ ពិតជាមានជំនាញនិងទំនួលខុសត្រូវ ព្រមទាំងបានអនុវត្តនូវវិធានការនៃច្បាប់បានច្បាស់លាស់ពិតប្រាកដមែន។ វាក៏ជាផ្នែកមួយយ៉ាងសំខាន់ក្នុងការជំរុញឱ្យអគ្គនាយកដ្ឋានពន្ធដារប្រមូលចំណូលចរន្តសរុបកើនឡើងនិងឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍ ដើម្បីត្រៀមខ្លួនក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នាពេលខាងមុខ។

ម្យ៉ាងវិញទៀត ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារមានដំណើរការផ្តល់នូវសេវាកម្មដែលមានគុណភាព ពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិប្រកបដោយតម្លាភាព រួមទាំងប្រសិទ្ធិភាពដើម្បីជម្រុញអ្នកជាប់ពន្ធឱ្យបំពេញនូវកាតព្វកិច្ចសារពើពន្ធដោយស្ម័គ្រចិត្ត។ ជាមួយគ្នានេះដែរបែបបទនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារត្រូវបានបូកផលរបបញ្ចូលគ្នា របស់សាខា និងសហគ្រាសមេដើម្បីគិតពន្ធប៉ាតង់ត្រូវបង់របស់សហគ្រាសបានយ៉ាងត្រឹមត្រូវច្បាស់លាស់។ យ៉ាងណាមិញយើងបានសង្កេតឃើញថាអគ្គនាយកដ្ឋានពន្ធដារផ្តល់សេវាឱ្យប្រជាពលរដ្ឋដោយស្មើភាព ភាពថ្លៃថ្នូរ និងការប្តេជ្ញាចិត្តដោយប្រើវិជ្ជាជីវៈ ជំនាញដល់ប្រជាពលរដ្ឋឱ្យមានភាពងាយស្រួល។ យើងក៏អាចមើលឃើញបានថាការប្រមូលពន្ធបានចូលរួមជំរុញកំណើនសេដ្ឋកិច្ចជាតិ ភាពរីកចម្រើន និងមានការអភិវឌ្ឍនូវក្នុងប្រទេស។

សរុបមក យោងតាមការសិក្សាស្រាវជ្រាវ និងពិភាក្សាគ្នាយ៉ាងសកម្មនៃសារណារបស់ក្រុមនាងខ្ញុំទៅលើប្រធានបទ "**ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ**" រួចមក ក្រុមរបស់នាងខ្ញុំអាចសន្និដ្ឋានបានថា ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ គឺពិតជាបានអនុវត្តឲ្យត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូលថវិការជាតិ ពិតប្រាកដមែន។

## ៥.២ ការផ្តល់អនុសាសន៍

បន្ទាប់ពីបានឆ្លងកាត់នូវការធ្វើសេចក្តីសន្និដ្ឋានស្តីពីការ ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារ រួចមកក្រុមយើងខ្ញុំក៏បានយល់ឃើញថា អគ្គនាយកដ្ឋានពន្ធដារបានគោរពទៅតាមគោលការណ៍របស់ខ្លួនបានយ៉ាងល្អិតល្អន់ ហ្មត់ចត់ ច្បាស់លាស់ និងត្រឹមត្រូវ ទៅតាមស្តង់ដារដែលបានដែលបានកំណត់និងអនុវត្តបានយ៉ាងល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ ក្នុងការប្រមូលពន្ធប៉ាតង់ ហើយក៏បានជួយជំរុញដល់ការអភិវឌ្ឍនប្រទេសកម្ពុជាថែមមួយកម្រិតទៀត យើងទាំងអស់គ្នាបានដឹងស្រាប់ហើយថា រាល់ការចំណាយមួយចំនួននៅក្នុងប្រទេសគឺសុទ្ធសឹងតែយកថវិកាដែលបានមកពីការប្រមូលដើម្បីទៅផ្គត់ផ្គង់ បើពុំមានប្រាក់ពន្ធនេះរាជរដ្ឋាភិបាលក៏ពិបាកក្នុងការផ្គត់ផ្គង់ចំណាយទាំងនេះដែរ ពោលគឺមិនអាចទប់ទល់នឹងចំណាយទាំងអស់នេះបានដែរ។ នៅពីខាងក្រោយនៃការជោគជ័យ និងច្បាស់លាស់ទៅតាមស្តង់ដារនៃពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ យើងក៏បានសង្កេតឃើញថាដំណើរការ នៃការប្រមូលពន្ធនេះនៅមានចំណុចខ្វះ

ខាតនិងត្រូវកែលំអរនៅឡើយបើយោងទៅតាមការយល់ឃើញរបស់ក្រុមយើងខ្ញុំ។ ហេតុដូច្នេះហើយ ក្រុមនាងខ្ញុំសូមបញ្ចេញមតិយោបល់មួយចំនួនដល់ ដំណើរការនៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារដែលស្ថិតនៅក្នុងន័យស្ថាបនាដើម្បីជួយជម្រុញឱ្យការងារ នៃការប្រមូលពន្ធប៉ាតង់របស់អគ្គនាយកដ្ឋានពន្ធដារកាន់តែមានប្រសិទ្ធភាពសុក្រឹត្យនិងបានកាន់តែល្អជាងមុនថែមមួយកំរិតទៀត ជៀសវាងមានការខ្វះចន្លោះកន្លែងណាមួយគួរតែប្រយ័ត្ន ដែលចំណុចទាំងអស់នោះរួមមានដូចខាងក្រោម៖

- មន្ត្រីពន្ធដារត្រូវតែគោរពពេលវេលា តួនាទីរបស់ខ្លួនឱ្យបានច្បាស់លាស់ដោយដឹងថាការងារណាសំខាន់ការងារណាមិនសូវសំខាន់ ការងារណាបន្ទាន់ ការងារណាមិនសូវបន្ទាន់ ដើម្បីទប់ស្កាត់នូវភាពយឺតយ៉ាវក្នុងការដាក់បញ្ជូនឯកសារឬរបាយការណ៍ជូនទៅកាន់ថ្នាក់លើឬអង្គភាព ដែលពាក់ព័ន្ធនានា។
- ពន្ធដារត្រូវតែពង្រឹង និងទទួលស្គាល់រាល់នៅចំណុចខ្វះខាតឬក៏មតិរិះគន់នានារបស់អ្នកជាប់ពន្ធក៏ដូចជាសាធារណៈជនដែលបានរាយការណ៍ឬក៏តាមរយៈមធ្យោបាយផ្សេងៗ។
- មិនត្រូវចាត់ទុកនូវចំណុចខ្វះខាតបន្តិចបន្តួចទោះបីកំហុសនោះប្រព្រឹត្តដោយចេតនាក្តី ឬអចេតនាក្តីជារឿងធម្មតា ហើយព្រងើយកន្តើយមិនព្រមផ្លាស់ប្តូរ ហេតុផលទាំងនេះហើយដែលជំរុញឱ្យការងារកាន់តែមានសក្តានុពល ។
- អគ្គនាយកដ្ឋានពន្ធដារត្រូវតែពង្រឹងទៅលើការត្រួតពិនិត្យរាល់ ក្រុមហ៊ុន សហគ្រាស និងជាពិសេសអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិច ឱ្យបានកាន់តែហ្មត់ចត់ដើម្បីជៀសវាងទៅលើការគេចវេសក្នុងការចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារ។

# ឯកសារយោង


- បណ្ណាល័យវិទ្យាស្ថានវ៉ាន់ដា
- https://www.facebook.com/100064079683016/posts/1609497449303329/
- https://www.tax.gov.kh/en
- https://www.facebook.com/100068406481464/posts/2011772108907527/
- https://www.kakcent.com/business-tax/
- https://registrationservices.gov.kh/media/2022/08/Prakas-on-Tax-Registration-and-Company-Update.pdf
- https://cambizian.com/2020/06/12/%E1%9E%A2%E1%9E%B6%E1%9E%87%E1%9E%B8%E1%9E%9C%E1%9E%80%E1%9E%98%E1%9F%92%E1%9E%98%E1%9E%8F%E1%9E%B6%E1%9E%98-online-%E1%9E%8F%E1%9F%92%E1%9E%9A%E1%9E%BC%E1%9E%9C%E1%9E%85%E1%9E%BB%E1%9F%87%E1%9E%94/

# ឧបសម្ព័ន្ធ


កាក់សេន
KAKCENT
ទំព័រដើម
ចំណូលចំណាយ
សន្សំ
វិនិយោគ
ហិរញ្ញវត្ថុ
ពន្ធនិងច្បាប់
ធានារ៉ាប់រង
ម៉ាស៊ីនគិតលេខ
ប្រភេទ ពន្ធនិងច្បាប់
ពន្ធប៉ាតង់
៤ ឆ្នាំមុន / 1 នាទីក្នុងការអាន / 1.6k ទស្សនា


CAMBIZIAN
Home
About
Services
Job
Our Partners
Contact
FAQ
Save
CAMBIZIAN®
ចុះបញ្ជី ម៉ាក
ប្រេន ស្លាកយីហោ
ដើម្បីបង្ការការលួចចម្លង និងក្លែងបន្លំ!
Register!
Logo
Trademark
& Brand
ទូរស័ព្ទទំនាក់ទំនង៖
070 268 276
095 806 670 / 096 903 2495
អាសយដ្ឋាន៖
ទីក្រុងអូឡាំព្យា ស៊ីធី, រាជធានីភ្នំពេញ
The Olympia City, Phnom Penh

| | | |
|---|---|---|
| ប្រកាស ស្តីពីវិធាននិងនីតិវិធីគ្រប់គ្រងប្រមូល**ពន្ធប៉ាតង់**<br>Prakas on the Rules and Procedures governing the Collection of Patent Tax | ១៨២១ សហវ.ប្រក \| 1821MEF Pr.K | អានលម្អិត |
| ប្រកាស ស្តីពីវិធានការនិងនីតិវិធីគ្រប់គ្រងប្រមូល**ពន្ធប៉ាតង់**<br>Prakas on Procedures on Patent Tax | ១៩៣ សហវ.ប្រក \| 193 MEF.PrK | អានលម្អិត |
| កម្មវិធី "ពន្ធដារកម្ពុជា" ស្តីពី**ពន្ធប៉ាតង់** និងពន្ធតែមប្រិ៍សារពើពន្ធ<br>GDT Cambodia Program on Patent Tax and Stamp Tax | ១៩៣ សហវ.ប្រក \| 193 MEF.PrK | អានលម្អិត |
| កម្មវិធី"ពន្ធដារកម្ពុជា" ស្តីពីកាតព្វកិច្ច**ពន្ធប៉ាតង់** និងការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស<br>Patent Tax Obligations and Enterprise Information Update | ១៩៣ សហវ.ប្រក \| 193 MEF.PrK | អានលម្អិត |
| **ពន្ធប៉ាតង់**<br>Patent Tax | ១៩៣ សហវ.ប្រក \| 193 MEF.PrK | អានលម្អិត |
| អនុក្រឹត្យ ស្តីពី**ពន្ធប៉ាតង់**<br>Sub-Decree on Patent Tax | ៤៧ អនក្រ.បក \| 47 ANKr.BK | អានលម្អិត |
| សៀវភៅស្តីពី "សកម្មភាពអាជីវកម្មកម្ពុជា និងកាតព្វកិច្ច**ពន្ធប៉ាតង់**" (ផ្នែកទី១)<br>Book on Business Activities in Cambodia and Patent Tax Obligations (part1)) | ៤៧ អនក្រ.បក \| 47 ANKr.BK | អានលម្អិត |

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ស្វែងរក

ទំព័រដើម / អ្នកជាប់ពន្ធ

## អ្នកជាប់ពន្ធ

១ ប្រជាពលរដ្ឋទូទៅ

អ្នកជាប់ពន្ធតូច ២

៣ អ្នកជាប់ពន្ធមធ្យម

អ្នកជាប់ពន្ធធំ ៤

## កាលបរិច្ឆេទផុតកំណត់ការបង់ប្រាក់ពន្ធ និងការដាក់លិខិតប្រកាសប្រចាំខែ-ឆ្នាំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...៧៦០.១...............សហវ.ប្រក

## ប្រកាស
## ស្តីពី
## ការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មជាបន្តបន្ទាប់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ. បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត បុគ្គលដែលត្រូវបានរដ្ឋបាលសារពើពន្ធចុះបញ្ជីជាឯកតោភាគី ដូចមានចែងក្នុងប្រការ១០ នៃប្រកាសនេះ ហើយមិនបានមកបំពេញកាតព្វកិច្ចចុះបញ្ជីឱ្យបានរួចរាល់ ត្រូវបានចាត់ទុកថាបានប្រព្រឹត្តបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលនឹងត្រូវទទួលរងទោសទណ្ឌស្របតាមមាត្រា១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

### ប្រការ ១៤.. និរាករណ៍

ប្រកាសលេខ ៤៩៦ សហវ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦ ស្តីពីការចុះបញ្ជីពន្ធដារ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

### ប្រការ ១៥..ការអនុវត្តប្រកាស

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក និងអគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអ្នកជាប់ពន្ធដែលមានចែងក្នុងប្រការ៤ នៃប្រកាសនេះ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចប្រការ ១៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សៀវភៅណែនាំ

# ស្តីពី

# ពន្ធប៉ាតង់

ឆ្នាំ ២០១៣

រៀបចំ និង បោះពុម្ពផ្សាយដោយ

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រក្សាសិទ្ធិគ្រប់បែបយ៉ាង

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ




# សកម្មភាពអាជីវកម្មកម្ពុជា និងកាតព្វកិច្ចពន្ធប៉ាតង់

២០២០

## បុព្វកថា

ស្ថិតក្នុងបរិយាកាសសុខសន្តិភាព ស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងការចង្អុលបង្ហាញដោយផ្ទាល់ជាប្រចាំរបស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានពន្ធដារបានចូលរួមអនុវត្តយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨។ ជាពិសេស នាពេលថ្មីៗកន្លងទៅនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ដែលមានទិសដៅធ្វើទំនើបភាវូបនីយកម្មប្រព័ន្ធចំណូលសារពើពន្ធ ដើម្បីឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ និងការវិវត្តនៃរចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ច។


បាត់ដំបង
ភ្នំពេញ
សៀមរាប
វិទ្យាស្ថាន វ៉ាន់ដា
VANDA INSTITUTE
ភាគ៣
គណនេយ្យអនុវត្តន៍ និងពន្ធ
ACCOUNTING PRACTICE &TAX
ក្រុមហ៊ុនផលិតកម្ម និងបញ្ជីគណនេយ្យសាមញ្ញ
MANUFATURING& SIMPLIFIED ACCOUNTING FORMAT
រក្សាសិទ្ធិគ្រប់យ៉ាងដោយវិទ្យាស្ថាន វ៉ាន់ដា
បោះពុម្ពលើកទី៣(២០២២)
សម្រាប់ប្រើប្រាស់ផ្ទៃក្នុង


ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន
បរិញ្ញាបត្ររង គណនេយ្យ
បរិញ្ញាបត្រ គណនេយ្យ
បរិញ្ញាបត្រ ភាសាអង់គ្លេស
(សញ្ញាបត្រ ២ កម្រិត)
បរិញ្ញាបត្ររងហិរញ្ញវត្ថុ និងធនាគារ
បរិញ្ញាបត្រហិរញ្ញវត្ថុ និងធនាគារ
អនុបណ្ឌិត គណនេយ្យ
អនុបណ្ឌិត សវនកម្ម
អនុបណ្ឌិត ពន្ធដារ
ភាពជោគជ័យនៅខាងមុខ!
ភ្នំពេញ
អគារលេខ ២១៦-២១៨ មហាវិថីម៉ៅសេទុង
សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
Tel: 023 213 563, Fax: 023 213 562
Vanda Institute of Accounting
សៀមរាប
អគារលឿង ផ្លូវ ៧មករា (ជន្លង់) ភូមិវត្តបូព៌
សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប
Tel: 017 370 268, Fax: 069 533 339
Vanda Institute Siem Reap Branch
បាត់ដំបង
ផ្ទះលេខ 271 ផ្លូវលេខ614 ភូមិរំចេក2
សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង
Tel: 053 732 563, Fax: 096 855 36 96
Vanda Institute of Battambang
www.vanda.edu.kh

# ឯកសារយោង

# ឯកសារយោង


- បណ្ណាល័យវិទ្យាស្ថានវ៉ាន់ដា
- https://www.facebook.com/100064079683016/posts/1609497449303329/
- https://www.tax.gov.kh/en
- https://www.facebook.com/100068406481464/posts/2011772108907527/
- https://www.kakcent.com/business-tax/
- https://registrationservices.gov.kh/media/2022/08/Prakas-on-Tax-Registration-and-Company-Update.pdf
- https://cambizian.com/2020/06/12/%E1%9E%A2%E1%9E%B6%E1%9E%87%E1%9E%B8%E1%9E%9C%E1%9E%80%E1%9E%98%E1%9F%92%E1%9E%98%E1%9E%8F%E1%9E%B6%E1%9E%98-online-%E1%9E%8F%E1%9F%92%E1%9E%9A%E1%9E%BC%E1%9E%9C%E1%9E%85%E1%9E%BB%E1%9F%87%E1%9E%94/

# ឧបសម្ព័ន

# ឧបសម្ព័ន្ធ


កាក់សេន
KAKCENT
ទំព័រដើម
ចំណូលចំណាយ
សន្សំ
វិនិយោគ
ហិរញ្ញវត្ថុ
ពន្ធនិងច្បាប់
ធានារ៉ាប់រង
ម៉ាស៊ីនគិតលេខ
ប្រភេទ ពន្ធនិងច្បាប់
ពន្ធប៉ាតង់
៤ ឆ្នាំមុន / 1 នាទីក្នុងការអាន / 1.6k ទស្សនា


CAMBIZIAN
Home
About
Services
Job
Our Partners
Contact
FAQ
Save
CAMBIZIAN®
ចុះបញ្ជី ម៉ាក
ប្រេន ស្លាកយីហោ
ដើម្បីបង្ការការលួចចម្លង និងក្លែងបន្លំ!
Register!
Logo
Trademark
& Brand
ទូរស័ព្ទទំនាក់ទំនង៖
070 268 276
095 806 670 / 096 903 2495
អាសយដ្ឋាន៖
ទីក្រុងអូឡាំព្យា ស៊ីធី, រាជធានីភ្នំពេញ
The Olympia City, Phnom Penh

| | | |
|---|---|---|
| ប្រកាស ស្តីពីវិធាននិងនីតិវិធីគ្រប់គ្រងប្រមូល**ពន្ធប៉ាតង់**<br>Prakas on the Rules and Procedures governing the Collection of Patent Tax | ១៨២១ សហវ.ប្រក \| 1821MEF Pr.K | អានលម្អិត |
| ប្រកាស ស្តីពីវិធានការនិងនីតិវិធីគ្រប់គ្រងប្រមូល**ពន្ធប៉ាតង់**<br>Prakas on Procedures on Patent Tax | ១៩៣ សហវ.ប្រក \| 193 MEF.PrK | អានលម្អិត |
| កម្មវិធី "ពន្ធដារកម្ពុជា" ស្តីពី**ពន្ធប៉ាតង់** និងពន្ធតែមប្រិ៍សារពើពន្ធ<br>GDT Cambodia Program on Patent Tax and Stamp Tax | ១៩៣ សហវ.ប្រក \| 193 MEF.PrK | អានលម្អិត |
| កម្មវិធី"ពន្ធដារកម្ពុជា" ស្តីពីកាតព្វកិច្ច**ពន្ធប៉ាតង់** និងការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស<br>Patent Tax Obligations and Enterprise Information Update | ១៩៣ សហវ.ប្រក \| 193 MEF.PrK | អានលម្អិត |
| **ពន្ធប៉ាតង់**<br>Patent Tax | ១៩៣ សហវ.ប្រក \| 193 MEF.PrK | អានលម្អិត |
| អនុក្រឹត្យ ស្តីពី**ពន្ធប៉ាតង់**<br>Sub-Decree on Patent Tax | ៤៧ អនក្រ.បក \| 47 ANKr.BK | អានលម្អិត |
| សៀវភៅស្តីពី "សកម្មភាពអាជីវកម្មកម្ពុជា និងកាតព្វកិច្ច**ពន្ធប៉ាតង់**" (ផ្នែកទី១)<br>Book on Business Activities in Cambodia and Patent Tax Obligations ( part1 ) ) | ៤៧ អនក្រ.បក \| 47 ANKr.BK | អានលម្អិត |

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ស្វែងរក



## អ្នកជាប់ពន្ធ

១ ប្រជាពលរដ្ឋទូទៅ

អ្នកជាប់ពន្ធតូច ២

៣ អ្នកជាប់ពន្ធមធ្យម

អ្នកជាប់ពន្ធធំ ៤

## កាលបរិច្ឆេទផុតកំណត់ការបង់ប្រាក់ពន្ធ និងការដាក់លិខិតប្រកាសប្រចាំខែ-ឆ្នាំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...៧០១...............សហវ.ប្រក

ប្រកាស

ស្តីពី

ការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មជាបន្តបន្ទាប់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភាព ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ. បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន



ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone : (+855)23 890 666

ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀត បុគ្គលដែលត្រូវបានរដ្ឋបាលសារពើពន្ធចុះបញ្ជីជាឯកតោភាគី ដូចមានចែងក្នុងប្រការ១០ នៃប្រកាសនេះ ហើយមិនបានមកបំពេញកាតព្វកិច្ចចុះបញ្ជីឱ្យបានរួចរាល់ ត្រូវបានចាត់ទុកថាបានប្រព្រឹត្តបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលនឹងត្រូវទទួលរងទោសទណ្ឌស្របតាមមាត្រា១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ ១៤._ និរាករណ៍**

ប្រកាសលេខ ៤៩៦ សហវ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦ ស្តីពីការចុះបញ្ជីពន្ធដារ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៥._ការអនុវត្តប្រកាស**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក និងអគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអ្នកជាប់ពន្ធដែលមានចែងក្នុងប្រការ៤ នៃប្រកាសនេះ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១០ រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចប្រការ ១៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សៀវភៅណែនាំ
# ស្តីពី
# ពន្ធប៉ាតង់

ឆ្នាំ ២០១៣

រៀបចំ និង បោះពុម្ពផ្សាយដោយ
អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រក្សាសិទ្ធិគ្រប់បែបយ៉ាង

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ




# សកម្មភាពអាជីវកម្មកម្ពុជា និងភាតព្វកិច្ចពន្ធប៉ាតង់

២០២០

## បុព្វកថា

ស្ថិតក្នុងបរិយាកាសសុខសន្តិភាព ស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងការចង្អុលបង្ហាញដោយផ្ទាល់ជាប្រចាំរបស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានពន្ធដារបានចូលរួមអនុវត្តយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨។ ជាពិសេស នាពេលថ្មីៗកន្លងទៅនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ដែលមានទិសដៅធ្វើទំនើបកម្មបរិយកម្មប្រព័ន្ធចំណូលសារពើពន្ធ ដើម្បីឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ និងការវិវត្តនៃរចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ចជាតិ។


បាត់ដំបង
ភ្នំពេញ
សៀមរាប
វិទ្យាស្ថាន វ៉ាន់ដា
VANDA INSTITUTE
ភាគ៣
គណនេយ្យអនុវត្តន៍ និងពន្ធ
ACCOUNTING PRACTICE &TAX
ក្រុមហ៊ុនផលិតកម្ម និងបញ្ជីគណនេយ្យសាមញ្ញ
MANUFATURING&SIMPLIFIED ACCOUNTING FORMAT
រក្សាសិទ្ធិគ្រប់យ៉ាងដោយវិទ្យាស្ថាន វ៉ាន់ដា
បោះពុម្ពលើកទី៣(២០២២)
សម្រាប់ប្រើប្រាស់ផ្ទៃក្នុង


ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន
បរិញ្ញាបត្ររង គណនេយ្យ
បរិញ្ញាបត្រ គណនេយ្យ
បរិញ្ញាបត្រ ភាសាអង់គ្លេស
(សញ្ញាបត្រ ២ កម្រិត)
បរិញ្ញាបត្ររងហិរញ្ញវត្ថុ និងធនាគារ
បរិញ្ញាបត្រហិរញ្ញវត្ថុ និងធនាគារ
អនុបណ្ឌិត គណនេយ្យ
អនុបណ្ឌិត សវនកម្ម
អនុបណ្ឌិត ពន្ធដារ
ភាពជោគជ័យនៅខាងមុខ!
ភ្នំពេញ
អគារលេខ ២១៦-២១៨ មហាវិថីម៉ៅសេទុង
សង្កាត់ទំនប់ទឹក ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
Tel: 023 213 563, Fax: 023 213 562
Vanda Institute of Accounting
សៀមរាប
អគារល្បឿន ផ្លូវ ៧មករា (ជន្លង់) ភូមិវត្តបូព៌
សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប
Tel: 017 370 268, Fax: 069 533 339
Vanda Institute Siem Reap Branch
បាត់ដំបង
ដីឡូត៍លេខ 271 ផ្លូវលេខ2614 ភូមិរំចេក2
សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង
Tel: 053 732 563, Fax: 096 855 36 96
Vanda Institute of Battambang
www.vanda.edu.kh